# កុលាបប៉ៃលិន

(*ប្រភពឯកសារ៖* http://www.khmerreader.com)

## វគ្គទី ១

## ជីវិតរបស់ក្មេងកំព្រា

គ្រានោះ ព្រះសុរិយទេវបុត្រ ទ្រង់គង់លើវិមានកែវផលិក (ផ្លេក) ដែលជារថព្រះទីនាំងទឹមដោយសេះអានេយ្យ១ពាន់ ទ្រង់បរប្រទក្សិណភ្នំព្រះសិនេរុរាជតាំងអំពីទិសបូព៌ា យាត្រាសំដៅទៅទិសបច្ចិមតាមចក្ររាសីនៃសុរិយចក្រវាឡ លុះដល់កំណត់ ក៏បត់ព្រះរាជរថចូលបាំងជ្រលងមហាបព្វតា រស្មីព្រះសុរិយាក៏ជ្រេងជ្រេចូលកាន់សន្ធ្យារាត្រី នាវេលានោះជាខាងខ្នើត ១៥កើត ខែកត្តិក ឆ្នាំច ចត្វាស័ក ព.ស ២៤៧០ ព្រះចន្ទទេវបុត្រយាងឡើងគង់លើវិមានប្រាក់ជារាជរថព្រះទីនាំង បរចេញមកពីទិសបូព៌ាឆ្លុះពណ៌ប្រាក់ទៅសព្វផែនពសុធា ព្រះចន្ទ្រាហាក់ដូចជាមៀងមើលមកយ៉ាងស្រស់ញញឹមឆ្ពោះចំទៅលើដំបូលគេហដ្ឋានមួយនៅខាងលិចផ្សារស្វាយប៉ោ ដែលជាផ្សារវិល ក្នុងទីរួមខេត្តបាត់ដំបង។
ឯគេហដ្ឋាននោះជាផ្ទះចាស់ប្រក់ក្បឿង ដំបូលពីរជាន់ ជញ្ជាំងក្តារ ក្រាលក្តារ សសរមូល នៅហោជាងមានរូបចម្លាក់ឈើធ្វើជារាហូលេបខែ នៅខាងក្រោមរូបនេះគេឆ្លាក់ជាអក្សរធំៗថា "សិរីពង្ស" ជាផ្ទះខ្មែរបែបបុរាណដែលនៅសេសសល់មកសម័យឥឡូវនេះ។

ក្នុងវេលារាត្រីនោះ ពន្លឺរស្មីនៃដួងចន្ទ្រាកំពុងចាំងឆ្លុះចូលមកតាមចន្លោះបង្អួចហើយមាន ខ្យល់ត្រជាក់បក់មកផាយផាត់ចូលមកយ៉ាងរំភើយៗ ល្ហើយត្រសៀកល្ហម ត្រជាក់ស្រួល នៅខាងក្នុងគេហដ្ឋាននោះមានកូនចង្កៀងប្រេងកាត១ ចងព្យួរនឹងជញ្ជាំងក្តារ ល្មមតែឆ្លុះបន្លឺឲ្យមើលមកឃើញបុរសជរាម្នាក់មានរាងកាយស្គាំងស្គមឥតសាច់ឈាម មានតែស្បែកដណ្តប់ឆ្អឹង ដេកស្តូកស្តឹងនាកណ្តាលល្វែងបន្ទប់ នៅក្បែរខាងបុរសជរានេះមានក្មេងប្រុសកំឡោះម្នាក់ មុខមាត់ស្រស់បស់ អង្គុយចាំបំរើថែរក្សាជម្ងឺរបស់បុរសជរាដោយកិរិយាឫកពាស្រពោនស្រពាប់ ស្រងូតស្រងាត់ ឥតមានរីករាយបន្តិចសោះដោយអ្នកខំអត់ងងុយទ្រាំជម្ងឺរបស់បុរសជរា ដែលត្រូវជាឪពុកបង្កើតរបស់ខ្លួន អស់វេលាពារាត្រីមកហើយ។
ឯបុរសដែលមានជម្ងឺជាទម្ងន់ កំពុងដេកស្តូកស្តឹងនៅលើដំណេកនេះឈ្មោះ "ចឹម" កំពុងតែធ្លាក់ខ្លួនទៅជាចំណីអាហារនៃរោគជរា យូរៗគាត់ដកដង្ហើមធំវែងៗ ហើយគាត់ខំបើកភ្នែក ក្រឡេកមើលទៅពាសពេញទាំងល្វែងបន្ទប់ដេក រួចភ្នែកទាំងគូរបស់គាត់សំឡឹងទៅចំមុខក្មេងកំឡោះម្នាក់ដែលអង្គុយនៅក្បែរខាងខ្លួនគាត់។ ឯកំឡោះនោះឈ្មោះចៅ "ចិត្រ" ជាកូនបណ្តូលចិត្តរបស់គាត់ ហើយជាអ្នកទទួលបន្តវង្សត្រកូលរបស់គាត់តទៅអនាគតផង ទើបគាត់ខំញញឹមទាំងក្រៀមក្រំ ប្រឹងនិយាយ

ដោយសូរសម្លេងញ័រៗថា "ចិត្រ" កូនមាសឪពុក! យប់យន់ណាស់ហើយមិនទាន់ទៅដេកទេឬ? ទៅកូន! ទៅដេកទៅ" តា ចឹម តឿនបង្ខំអោយកូនទៅដេក ក្រែងអត់ងងុយទៅជាឈឺចាប់។
ចៅចិត្រគ្រវីក្បាលដោយការបដិសេធ ព្រមទាំងមានទឹកមុខប្រកបដោយ ចិត្តអាណិតអាសូរបិតា ទើបនិយាយជំរាបទៅវិញថា "ខ្ញុំបាទមិនទាន់ងងុយទេលោកឪពុក! ប្រហែលជាលោកឪពុកមិនទាន់ពិសាថ្នាំយោងកម្លាំងទេដឹង? លោកគ្រូពេទ្យបានផ្តាំខ្ញុំបាទថា សូមឲ្យលោកឪពុកពិសាកុំខាន"។
"ថ្នាំឬកូន?" តាចឹមនិយាយឮតែក្នុងបំពង់កទំនងចំអកឲ្យថ្នាំនោះ ព្រោះជាថ្នាំគាត់ដឹងថាឥតមានគុណវិសេសអ្វីបន្តិចឡើយ ហើយគាត់និយាយថា "ឱ!កូនអើយ ថ្នាំនេះឪពុកបានផឹកមកច្រើនលើកមកហើយ មិនឃើញមានគុណវិសេសអ្វីដែលអាចជួយបន្ធូរបន្ថយជម្ងឺឲ្យស្រាកស្រាន្តសោះឡើយ រោគជំពូកនេះ ឪស្គាល់ច្បាស់ថាជារោគប្រចាំកាយ រក្សាក៏ស្លាប់ មិនរក្សាក៏ស្លាប់ ឫទ្ធិអំណាចរបស់ថ្នាំក្នុងខណៈនេះមិនវិសេសជាងទឹកទន្លេទេកូន"។
ចៅចិត្រមិនទាន់តបទៅឪពុកវិញ ស្រាប់តែលេចបុរសកណ្តាលអាយុម្នាក់ ដើរចូលមកក្នុងបន្ទប់ ហើយដាក់គូថអង្គុយក្បែរខាងអ្នកជំងឺ ហើយសួរថា "ម៉េចទៅតា ថ្ងៃនេះអាការរោគបានធូរស្បើយខ្លះទេ?"។
"ឱពុទ្ធោ! ពុទ្ធោ!" តាចឹមលាន់មាត់ឡើងកាលបានឮលោកគ្រូពេទ្យសួរខ្លួនដូច្នេះ ហើយគាត់និយាយទៅទៀតថា "ឱ! លោកគ្រូអើយ! វេលានេះភ្នែកខ្ញុំបាទស្លែស្រវាំងងងឹតអស់ ហើយសូមអត់ទោសចុះ ខ្ញុំបាទមិនដឹងថាលោកគ្រូអង្គុយនៅត្រង់ណាទេ"។
ឯចៅចិត្រ កាលបើបានឮសំដីឪពុកនិយាយគួញគ្នេរដូច្នោះ ទឹកភ្នែកក៏ហៀរហូរសស្រាក់ ដោយចិត្តអាណិតឪពុកពន់ពេក ហើយក៏សំឡឹងមើលគ្រូពេទ្យ និយាយអង្វរករសុំឲ្យជួយស្រោចស្រង់សង្គ្រោះបិតាឲ្យមានជីវិត តែគ្រូពេទ្យដែលស្ទាត់ជំនាញក្នុងវិធីមើលជម្ងឺ ក៏គ្រវីក្បាលដោយអស់សង្ឃឹមខ្សឹបប្រាប់ជិតត្រចៀកចៅចិត្រថា "ឆ្លងមិនផុតពីយប់នេះទេ"។
តាចឹមនិយាយមួយៗ ទាំងមាត់ជង្ហក់បបូរមាត់ស្លាំងញ័រចំប្រប់ ខំនិយាយទៀតថា "ខ្ញុំបាទគង់មិនមានជីវិតរស់នៅទាល់តែបានឃើញពន្លឺព្រះអាទិត្យក្នុងព្រឹកស្អែកនេះទៀតទេ ខ្ញុំបាទយល់ថាមិនមែនការចំលែកខុសធម្មតាទេ ព្រោះមរណធម៌ជាសភាវៈទៀងទាត់ ដែលមនុស្សសត្វទូទៅត្រូវទទួលយកនឹងចៀសវាងឲ្យផុតពុំបានឡើយ ឯវិញ្ញាណនិងរាងកាយរបស់ខ្ញុំបាទឥតមានស្រណោះអាឡោះអាល័យប៉ុន្មានទេ ស្លាប់ហើយត្រូវទៅកើតជាអ្វីក៏តាមយថាកម្មចុះ ..." ហើយបែរទៅនិយាយផ្តែផ្តាំកូនថា "ចិត្រ កូនសំលាញ់ឪពុក! កាលបើឪពុកអស់អាយុទៅហើយ ជីវិតកូនមុខតែរសាត់អណ្តែតឥតបង្គោលជាបង្អែក ដូចជាសំណាត់ដែលអណ្តែតក្នុងទន្លេដូច្នោះ"។
ឯចៅចិត្រអួលដើមកនិយាយអ្វីមិនរួចសោះ មានតែទឹកភ្នែកហូរសស្រាក់ ឱនមុខជ្រប ក្រាបចុះជិតជើងឪពុក។ ចំនែកខាងគ្រូពេទ្យ ក៏ងាកមុខបែរទៅបង្អួច ស្ទើរតែទ្រាំទប់ទឹកភ្នែកពុំបាន។
តាចឹមនិយាយទាំងហត់ថា "នែ ចិត្រ! កូនសំឡាញ់ឪពុក កាលបើឪពុកស្លាប់ទៅហើយ ចូរចាំបណ្តាំឪពុកចុះថា ធម្មជាតិគ្រប់យ៉ាងក្នុងលោកនេះ ដែលមនុស្សលោកសំគាល់ថាជាការរុងរឿង

ថ្លៃថ្លានោះ គឺជាការតាំងខ្លួនប្រាណឲ្យបានថ្លៃថ្នូរស្អុកស្អម្ភ ... ឯការដែលរស់នៅតោកយ៉ាកនោះ អ្នកផងទាំងពួងគេមិនយកភ្នែកមើលទេ ការរស់នៅបែបនេះ មិនមែននាំឲ្យបានសុខសប្បាយទេ ប៉ុន្តែពេលនេះ កូនអើយ! ឪពុកនឹងប្រាប់អ្នក ឲ្យធ្វើដូចម្តេចទើបបានសេចក្តីចំរើននោះពុំបានទេ សុំអោយគ្រាន់តែលើកដល់ពុទ្ធភាសិត១បទថា "អត្តាហិអត្តនោនាថោ" ខ្លួនត្រូវទីពឹងខ្លួនតែប៉ុណ្ណោះ ឲ្យរឿយៗចុះ ... កូនអើយ ពាក្យនេះមានន័យថា លោកមិនមែនទូន្មានយើងឲ្យគិតតែប្រយោជន៍ផ្ទាល់ខ្លួន ឲ្យទៅជាមនុស្សទត្តភាពនោះទេ ឬលែងឲ្យពឹងពាក់អ្នកដទៃ ឬលែងឲ្យអ្នកដទៃពឹងពាក់លើខ្លួនយើងវិញក៏ទេដែរ។ ពុទ្ធភាសិតនេះ ទូន្មានយើងឲ្យចេះខំប្រឹងប្រែងកសាងជីវភាពខ្លួនឲ្យបានចំរើន ឲ្យមានជំហររឹងប៉ឹងដោយវិជ្ជាសម្បត្តិ គុណសម្បត្តិ សម្ថភាព ទ្រព្យសម្បត្តិ និង សុខភាព ទើបយើងអាចរស់នៅក្នុងសង្គមមនុស្សបានថ្លៃថ្នូរ ហើយយើងអាចផ្តល់បាននូវអត្ថប្រយោជន៍ឬគុណប្រយោជន៍ដល់សង្គមឲ្យបានចំរើនឡើងទៀតផង។ កូនដឹងស្រាប់ហើយថា មនុស្សកើតមកក្នុងលោកនេះ មិនមានអ្នកណាមួយអាចរស់នៅតែម្នាក់ឯងបានទេ គឺត្រូវមានការពឹងពាក់ទាក់ទងគ្នាទៅវិញទៅមកជានិច្ច កូនត្រូវស្គាល់ហើយត្រូវខំបំពេញករណីកិច្ចរបស់ខ្លួនចំពោះខ្លួនឯង ចំពោះសង្គម ចំពោះជាតិ ចំពោះសាសនា មហាក្សត្រ ដែលជាឧត្តមគតិរបស់ពលរដ្ឋជាតិយើង ហើយចំពោះមនុស្សជាតិទូទៅ ដែលជាឧត្តមគតិនៃព្រះពុទ្ធសាសនា"។

ឯគ្រូពេទ្យនិយាយជ្រែកក្នុងខណៈនោះថា "តាកុំអាលអស់សង្ឃឹមរហ័សពេក រោគរបស់តាដែលធ្ងន់ដូច្នេះ ក៏មិនទាន់ទៅជាអ្វីទេ នៅមានសង្ឃឹមនឹងសះស្បើយវិញបាន"។

តាចឹមនិយាយផ្អើនលោកគ្រូពេទ្យ "សះជាឬ? លោកគ្រូ គ្មានផ្លូវសះជាឡើងវិញប្រាកដមានតែផ្លូវស្លាប់? មុខក្នុងព្រឹកស្អែកឬយប់នេះឬឥឡូវនេះ ក្នុងពេលណាមួយជាមិនខាន"។ តាចឹមឈប់បង្អង់មួយស្របក់ ហើយចាប់និយាយតទៅទៀតថា "នែ! ចិត្រ កូនសំឡាញ់ឪពុក ឪពុកទីទ័លក្រណាស់ គ្មានកេរមត៌កបន្តិចបន្តួចបម្រុងទុកឲ្យកូនឡើយ ដល់ឪពុកស្លាប់ទៅហើយ មានតែសពនិងពាក្យបណ្តាំទុកឱយកូន ... រីឯវិញ្ញាណក្ខន្ធរបស់ឪពុកដែលនឹងបានទទួលសេចក្តីសុខក្សេមក្សាន្ត ក្នុងលោកខាងមុខនោះ លុះតែកូនប្រតិបត្តិតាមបណ្តាំឪពុកទាំងប៉ុន្មានម៉ាត់នេះ ដែលជាបណ្តាំចុងក្រោយបំផុតរបស់បិតា មួយទៀតវិជ្ជាដែលឪពុកទុកដាក់អោយកូនរៀនសូត្រដរាបទាល់តែប្រឡងជាប់ប្រកាសនីយប័ត្រនោះ ទុកជាមត៌កដ៏មានតំលៃមួយ ឱ! តាំងពីថ្ងៃនេះទៅឪពុកអស់បានជួយទំនុកបំរុងកូនតទៅទៀតហើយ!"

ចៅចិត្រ កាលបើស្តាប់ពាក្យបណ្តាំរបស់ឪពុកចប់សព្វគ្រប់ហើយក៏ស្រក់ទឹកភ្នែកប្រោកៗ ដោយមានចិត្តអាល័យ និងអាណិតឪពុកជាទីបំផុត ហើយខំនិយាយទាំងខ្សឹកខ្សួល ជំរាបឪពុកថា "លោកឪពុក! បណ្តាំគ្រប់ម៉ាត់ ខ្ញុំបាទនឹងកត់ត្រាចាំទុកក្នុងចិត្ត ខិតខំប្រតិបត្តិតាមបណ្តាំគ្រប់ប្រការ សូមលោកឪពុកកុំបីព្រួយបារម្ភឡើយ ខ្ញុំបាទបានជីវិតរស់នៅដរាបណានឹងខំតាំងខ្លួនប្រាណដំកល់ដំកើងវង្សត្រកូលអោយបានចំរើនដរាបនោះ"។

តអំពីពេលនោះមក តាចឹមមានការជង្គក់កាន់តែញឹកញាប់ខ្លាំងឡើង មានអាការក្រេវល់ក្រវាយទំនងស្លឈាម ហើយទន់ពាប់ទៅរាល់គ្រាមរណសង្គ្រាមកំពុងទន្ទ្រានចូលមកជិតអ្នកជម្ងឺគ្រប់ដង្ហើម ទើបគាត់ខំប្រឹងនិយាយទៅកេគ្រូពេទ្យ ដែលមានចិត្តមេត្តាចំពោះខ្លួន ដោយសូរសំលេងខ្សាវៗ ជាទំនងសេចក្តីថា "ទានប្រោស លោកគ្រូ! ខ្ញុំបាទនឹងដាច់ខ្យល់ស្លាប់ក្នុងពីរ-បីនាទីនេះហើយ សូមអរព្រះគុណ និងសូមជូនបុណ្យលោកគ្រូ ដែលមានគុណលើខ្លួនខ្ញុំបាទជាអនេក ដោយបានខំថែរក្សាទាំងបង់ខាតថ្លៃថ្នាំជាច្រើនផង ហើយមិនមានគិតថ្លៃរក្សា និងថ្លៃថ្នាំបន្តិចឡើយ ខ្ញុំបាទឥតមានអ្វីតបស្នងសងគុណលោកគ្រូទេ ឱ! ព្រះគុណអើយ ត្រចៀកខ្ញុំបាទលែងឮហើយ ឱ! ចិត្រកូន! ពុទ្ធោអរហំ!"។

ថៅចិត្រឱបឪពុកជាប់ ហាក់ដូចជាមិនព្រមអោយវិញ្ញាណក្ខន្ធរបស់តាចឹមរត់ចេញពីរាងកាយទៅបាន តែបើទុកជាថៅចិត្រខំប្រឹងទប់ទល់យ៉ាងណា ក៏គង់តែមិនសំរេចដូចបំណង ព្រោះជាតិជរា ព្យាធិ មរណៈ (កើត ចាស់ ឈឺ ស្លាប់) ជាមត៌ករបស់សត្វលោក ឥតមានសត្វណាមួយគេចវេស ចៀសវាងឲ្យរួចផុតទៅបានឡើយ អម្បាលដូចយ៉ាងព្រះអរហំសម្មាសម្ពុទ្ធម៉េចក៏គង់តែព្រះអង្គចូលបរិនិព្វានមិនខាន។

នៅទីបំផុតនេះ តាចឹមក៏ធ្លាក់ខ្លួនទៅជាចំណីអាហារនៃមច្ចុរាជ គឺដាច់ខ្យល់ ផុតដង្ហើម ក្នុងដៃរបស់ថៅចិត្រជាកូន។ តាចឹមក៏ទទួលមរណភាពក្នុងខណៈដែលដួងចន្ទ្រអស្តង្គតបាត់ពន្លឺរស្មីព្រមជាមួយគ្នាក្នុងគ្រានោះឯង។

កាលបានចាត់ចែងធ្វើបុណ្យបូជាសពរួចស្រេចហើយ ទើបថៅចិត្រដឹងខ្លួនច្បាស់ណាស់ថា "ឱ! ខ្លួនអញអើយ កណ្តែងកណ្តោចខ្លោចផ្សាតែម្នាក់ឯងហើយ បើងាកររេទៅពឹងបងប្អូនញាតិសាច់លោហិតជិតខាងឯណាក៏គ្មាន ... ណ្ហើយចុះត្រូវតែតស៊ូនឹងសេចក្តីទុក្ខលំបាកគ្រប់យ៉ាងចុះ ធ្វើម្តេចកើតមកជាប្រុសកំព្រាម្តាយឪពុក សមដូចជាប្រសាសន៍លោកឪពុកផ្តាំទុកថា "ចិត្រ កូន! កាលបើអស់បុណ្យពីឪពុកហើយ ជីវិតរបស់អ្នកដូចកំណាត់ឈើ ដែលអណ្តែតក្នុងកណ្តាលទន្លេដូច្នោះ ..."។

ថៅចិត្រក៏គិតឃើញថា ពិភពលោកទាំងមូលនេះធំទូលាយស្រួលសប្បាយមែនសម្រាប់អ្នកដទៃៗ តែបែរជាទៅជាទីតូចចង្អៀត លំបាកពន់ពេកចំពោះខ្លួនដែលកំព្រាម្តាយឪពុកនិងបងប្អូនញាតិសាលោហិត នឹងងាកមុខទៅជ្រកកោនពឹងពាក់អ្នកឯណាក៏គេឥតត្រូវការសោះ ព្រោះមនុស្សទីទ័លក្រលំបាកដូចនេះ គេមិនត្រូវការសេពគប់រាប់រក ហើយទុកជាសុំការគេធ្វើ ក៏ឥតមានអ្នកណាជួយសង្គ្រោះរកការងារឲ្យធ្វើបានឡើយ។ ឱ! ខ្លួនអញអើយកើតមកក្នុងលោកនេះលំបាកអ្វី ប្លែកជាងគេម្ល៉េះ តែថាកើតជាអង្គបុរសហើយ មិនត្រូវខ្លាចសេចក្តីទុក្ខព្រួយលំបាកទេ តោងតែតស៊ូនឹងសេចក្តីទុក្ខព្រួយលំបាកអស់នេះឲ្យឃើញសខ្មៅទៅចុះ!។

ចៅចិត្រ កំពុងតែឈរសញ្ជឹងរំពឹងគិតរកការធ្វើតែម្នាក់ឯងយ៉ាងស្ងាត់ៗ នៅចំហៀងមុខផ្ទះ ក៏ងើយទៅមើលលើឃើញព្រះចន្ទអណ្តែតត្រសែតនៅកណ្តាលពពក បញ្ចាំងបន្លឺឆ្លុះសព្វទិសទីបរិវេណ មានខ្យល់បក់ផាត់មកយ៉ាងត្រជាក់ស្រេង ឮសូរសំឡេងព្រះសង្ឃសូត្រធម៌នៅវត្តព្រះពិភិជារាមយ៉ាងច្បាស់លាស់ អណ្តែតលឿនលយមកតាមបណ្តោយខ្យល់ លុះចៅចិត្របានឮសូរស័ព្ទព្រះសង្ឃសូត្រធម៌នោះក៏ជាហេតុនាំផ្តួចឲ្យនឹករលឹកដល់ឪពុក ដែលទើបទទួលអនិច្ចកម្មទៅថ្មីៗ មិនដឹងបើនឹងងាករបែរមុខទៅពឹងអ្នកឯណា ហើយក៏បែរមុខមើលទៅក្នុងបន្ទប់ឃើញមានចង្កៀងភ្លឺថ្លុងៗ នៅទីនោះហើយដែលជាទីឪពុកធ្លាប់មូរថ្នាំសង្កៃពិសាជានិច្ច តែឥឡូវនេះ មានតែចៅចិត្រម្នាក់ឯង ចិត្រអាណិតខ្លួនណាស់ទឹកនេត្រាក៏ហូរចេញសស្រាក់ដោយឥតដឹងខ្លួន។

ខណៈនោះ ចៅចិត្រក្រឡេកមើលទៅខាងមុខស្រាប់តែឃើញមនុស្សម្នាក់ ស្លៀកពាក់ស ដើរចូលមកទើបចៅចិត្រ ក្រោកឡើងស្រែកសួរថាៈ "នរណានុះ?"

"គ្នាឯងទេ ចៅចិត្រ ឬអីហ្នឹង?" បុរសនោះសួរមកវិញ។

ចៅចិត្រនឹកស្មានប្រហែលជាលោកគ្រូពេទ្យ ទើបស្រែកអញ្ជើញថា "សូមអញ្ជើញលោកគ្រូ"។

គ្រូពេទ្យក៏ឈានជើងឡើងជណ្តើរទៅលើផ្ទះ ហើយដាក់គូទអង្គុយលើកៅអី តាមសេចក្តីអញ្ជើញរបស់ម្ចាស់ផ្ទះ។

"សុខសប្បាយជាទេឬ ចៅចិត្រ?" គ្រូពេទ្យសួរដោយមេត្រីចិត្ត។

ចៅចិត្រតបថា "ទានប្រោស! ចំណែកខាងរាងកាយសុខសប្បាយទេ ប៉ុន្តែចំណែកចិត្ត វេងកម្មជាទីបំផុត ឥតសប្បាយមួយពេលឡើយតាំងអំពីលោកឪពុកអនិច្ចកម្មទៅ វិញ្ញាណរបស់ខ្ញុំបាទនេះហាក់ដូចជាងងឹតឈឹងពុំដឹងអ្វីឡើយ!"។

គ្រូពេទ្យងក់ក្បាលទំនងជឿតាមសំដីចៅចិត្រ ទើបសួរថែមទៀតថា "ចុះសព្វថ្ងៃនេះ បានធ្វើការនៅកន្លែងណាហើយឬនៅឡើយទេ?"

ចៅចិត្រនិយាយតបដោយក្រៀមក្រំសោះកក្រោះថា "ទានប្រោស! នៅទីនេះ ខ្ញុំបាទរកការងារធ្វើមិនទាន់បានទេ ការងារគ្រប់ផ្នែកហាក់ដូចជាខ្ពស់ជាងចំនេះដឹងរបស់ខ្ញុំបាទ ដែលបានខំរៀនសូត្រមកដូចជាច្រើនណាស់ ហាក់ដូចគ្រាន់តែប្រើការបានត្រឹមតែមើលសំបុត្រស្នាមបន្តិចបន្តួច មើលឈ្មោះហាងរានផ្សេងៗ និង មើលប្រូក្រាមតាមរោងកុន ល្មមប៉ុណ្ណោះ!"។

គ្រូពេទ្យនិយាយដោយសេចក្តីអាណិត យ៉ាងស្មោះត្រង់ថា "ខ្ញុំក៏នឹកអាណិតអ្នកច្រើនណាស់ដែរ ចិត្រ" ហើយនិយាយទូន្មានថា "ខ្លួនអ្នកជាកូនប្រុស ត្រូវតទល់នឹងវិស័យលោកិយទៅមុខទៀតច្រើនណាស់បង្អង់ឲ្យខ្ញុំគិតពីរ បីនាទីមើល ក្រែងខ្ញុំគិតរកឧបាយ ជួយសង្គ្រោះខ្លួនអ្នកឯងបានខ្លះ"។

ចៅចិត្រនៅតែស្ងៀម គ្រូពេទ្យសញ្ជឹងគិតមួយស្របក់ ក៏ញញឹមលាន់មាត់ ចេញសំដីថា នឹកឃើញហើយ នឹកឃើញហើយ! ខ្ញុំមានឪពុកមាម្នាក់ជាអ្នកមានចិត្តសប្បុរស មានសម្បត្តិស្តុកស្តម្ភគ្រាន់បើ មើលទៅបើលោកជួយធុរៈ មុខជាអ្នកឯងបានការងារធ្វើមិនខាន តែតោងនឿយហត់បន្តិចមុនដំបូង"។

ថៅចិត្រញញឹមញញែម ហើយជំរាបសួរទៅលោកគ្រូពេទ្យថា "ខ្ញុំបាទទទួលអត់ធន់សេចក្ដីលំបាកទាំងអស់ សុំឲ្យមានតែការធ្វើនឹងគេចុះ គ្រាន់នឹងបានចិញ្ចឹមជីវិត កុំឲ្យមានពាក្យគេតិះដៀលប៉ុណ្ណោះ ទុកជាជីកដីលីសែង រែក ពុនយ៉ាងណាក៏ដោយក៏ខ្ញុំបាទស្ម័គ្រធ្វើទាំងអស់"។

លោកគ្រូពេទ្យមានទឹកមុខរីករាយ ដោយសេចក្ដីពេញចិត្តហើយថា "ខ្ញុំគិតជានិច្ចថា អ្នកឯងជាកូនប្រុស អាចទទួលធ្វើការគ្រប់ជំពូកបាន គំនិតអ្នកឯងគួរឲ្យសរសើរណាស់ ប៉ុន្តែ ថៅចិត្រ! ការដែលអ្នកឯងត្រូវធ្វើនោះ មិនមែននៅទីនេះទេ គឺនៅឯស្រុកបប៉ៃលិនឯណោះ"។

"បប៉ៃលិនឬ ទានប្រោស!" ថៅចិត្រឆ្លើយផ្ទួនពាក្យបាត់ទឹកមុខញញឹមរីករាយមួយរំពេច ហើយនិយាយត្អូញត្អែថា "ទានប្រោស! គេថាស្រុកនោះចាញ់ណាស់ មានតែពួកភូមា កូឡា ទើបទ្រាំទៅរកស៊ីក្នុងទីនោះបាន ខ្ញុំបាទនឹកក្រែងតែទ្រាំទ្រនឹងធាតុអាកាសទឹកដីនោះមិនបានទេដឹង?"

គ្រូពេទ្យទូន្មាន "អ្នកឯងនិយាយដូច្នេះក៏ត្រូវដែរ ប៉ុន្តែអ្នកដែលទៅហើយឈឺចាញ់នៅទីនោះ ច្រើនធ្វេសប្រហែស មិនចេះរក្សាខ្លួនឲ្យផុតពីជម្ងឺគ្រុនចាញ់ ចុះចំណែកអ្នកឯងក៏បានរៀនសូត្រចេះក្បួនអនាម័យមកខ្លះ ក៏ល្មមនឹងការពារខ្លួនបាន មួយវិញទៀតជម្ងឺគ្រុនចាញ់នេះ មិនចំពោះតែជាតិយើងទេ ទុកជាជាតិណាក៏ដោយ តែខ្វះវិធីការពាររោគតាមក្បួនអនាម័យហើយ មុខជាឈឺចាប់ដូចគ្នាទាំងអស់"។ គ្រូពេទ្យនិយាយទូន្មានថៅចិត្រឲ្យមានភាពក្លាហានឡើង ហើយពោលទៅទៀតថា "ឪពុកមាខ្ញុំនោះ ពីដើមបានធ្វើមន្ត្រីមួយហៅតាមបណ្ដាសក្ដិថា "ហ្លួងរតនសម្បត្តិ" វេលានេះ អាយុលោក ៥០ប្លាយឆ្នាំហើយ លោកមានអធ្យាស្រ័យល្អ ពួកកូឡា ភូមា នៅទីនោះរាប់អានលោកណាស់ កាលពី២ទៅ៣អាទិត្យមុននេះ លោកមានសំបុត្រមកដល់ខ្ញុំ សុំឲ្យរើសរកមនុស្សម្នាក់ទៅធ្វើការលោក ចំពោះរូបអ្នកឯងមួយនេះខ្ញុំទុកចិត្តណាស់ ត្បិតការជីកត្បូងនីមួយៗ គេត្រូវការតែមនុស្សសុចរិតស្មោះត្រង់។

ថៅចិត្រនិយាយថា "ការនេះ ជាការថ្មោងថ្មីក្នុងជីវិតរបស់ខ្ញុំបាទ"។

គ្រូពេទ្យថា "គ្រាន់បើជាងនៅទំនេរ មិនទាន់មានការអ្វីធ្វើមែនទេ? បើព្រមទទួល ខ្ញុំនឹងចាត់បញ្ជូនអ្នកឯងនៅវេលាឆាប់ៗនេះ ដោយខ្ញុំមានសេចក្ដីសង្ឃឹមទុកចិត្តថា អ្នកនឹងខិតខំធ្វើការយ៉ាងម៉ឺងម៉ាត់ ជាទីពេញចិត្តរបស់គេពុំខាន"។

ថៅចិត្រលើកដៃសំពះ ថ្លែងអំណរគុណដោយសេចក្ដីគោរពចំពោះលោកគ្រូពេទ្យ គ្រូពេទ្យក៏សរសេរសំបុត្រមួយច្បាប់ ឲ្យថៅចិត្រហើយលាចុះដើរចេញពីផ្ទះនោះទៅ។

# វគ្គទី ២

## ការធ្វើដំណើរទៅប៉ៃលិន

លុះចៅចិត្របានទទួលសំបុត្រគ្រូពេទ្យហើយ ក៏ចាត់ចែងសំពត់អាវដាក់វ៉ាលីសផ្ដៅ និងអីវ៉ាន់សម្រាប់ធ្វើដំណើរទៅរួចស្រេចហើយ ក៏ប្រះដេកសំរាកដោយសេចក្ដីត្រេកអរដ៏លើសលប់ក្នុងយប់នោះ ស្ទើរតែដេកមិនលក់ទល់ភ្លឺ។ ដល់ម៉ោង៥ជិតភ្លឺ នាឡិកាឯផ្សារវិលវាយឮសូរម៉ឹងៗយ៉ាងច្បាស់លាស់រហូតដល់ផ្ទះចៅចិត្រ ចៅចិត្រ ក្រោកឡើងលុបលាងមុខមាត់រួច ក៏ស្លៀកពាក់ យួរវ៉ាលីសចុះពីផ្ទះ ដើរសំដៅទៅផ្សារវិល បំរុងទៅឡើងរថយន្តដែលដើរទៅផ្លូវបាត់ដំបងបប៉ៃលិន។
ចៅចិត្រទិញសំបុត្រកន្លែងរួចស្រេចហើយក៏អង្គុយចាំដរាបដល់ពេលរថយន្តចេញពីផ្សារក្រុងបាត់ដំបងទៅ។ វេលាម៉ោង ៦និង ១៥នាទី រថយន្តក៏បើកចេញសំដៅទៅទិសខាងត្បូង ដល់ទៅផ្សារភាសុីស្រាក៏បត់ត្រង់ទៅលិច តាមផ្លូវបប៉ៃលិន។ ចៅចិត្រអង្គុយមើលភូមិប្រទេសសងខាងមាគ៌ានោះមុខគួរឲ្យស្រងេះស្រងោច អណ្ដែតអណ្ដូងក្នុងចិត្តជាចំឡែកណាស់ នឹកដល់ឪពុកដែលទើបអនិច្ចកម្មទៅថ្មីៗកាលណា ទឹកភ្នែកក៏ជោរជន់ចេញមក តែខំទប់ទល់មិនឲ្យទឹកភ្នែកស្រក់ចុះទាល់តែបាន ដើម្បីការពារកុំឲ្យអ្នកជិះរថយន្តជាមួយគ្នាមានសេចក្ដីសង្ស័យមន្ទិលមកលើខ្លួន ហើយបន្លំនិយាយសើចលេងកំសាន្តជាមួយនឹងអ្នកជិះទាំងអស់គ្នារៀងៗទៅ។
ឯផ្លូវដែលឡើងទៅស្រុកបប៉ៃលិនមិនសូវឆ្ងាយប៉ុន្មានពីក្រុងបាត់ដំបងក៏ពិតមែន តែជាផ្លូវលំបាកបន្ដិចត្បិតត្រូវបររថយន្តឡើងកាត់ភ្នំនិងសសៀរតាមជើងភ្នំខ្ពស់ឡើងៗ ហើយកោងបរបត់បែនដរាបដល់ស្រុកបប៉ៃលិន ទុកជាបង្ខំយ៉ាងណាក៏គង់តែរថយន្តរត់មិនលឿនរហ័សដូចផ្លូវរាបទេ។ ចៅចិត្រក្រឡេកមើលទេសភាពតាមសងខាងផ្លូវ សឹងដេរដាសទៅដោយស្រែចំការច្បារដំណាំ និងភូមិស្រុកដោយអន្លើៗ ឃ្លាតឆ្ងាយដាច់ៗពីគ្នា លុះជិតទៅដល់បប៉ៃលិនក៏ឃើញតែព្រៃព្រឹក្សាលតាវល្លិ៍ និងភ្នំតូចធំច្រើនអនេក ព្រមទាំងសត្វបក្សាបក្សីនិងសត្វចតុប្បាទក៏មានកុះករច្រើននៅតាមដងព្រៃព្រឹក្សាអស់នោះ។ ចៅចិត្របានឃើញសត្វអស់នោះ ក៏កើតមានចិត្តសង្វេគនឹករលឹកដល់ឪពុកកាន់តែខ្លាំងឡើងៗ ស្ទើរតែទប់ទឹកភ្នែកពុំបាន។

លុះដល់រថយន្តបរបើកកាត់ព្រៃភ្នំក្រំថ្មជាច្រើនអន្លើ វេលាម៉ោង១១ថ្ងៃត្រង់ រថយន្តក៏បានទៅដល់ផ្សារបប៉ៃលិនដោយស្រួល។ ចៅចិត្រចុះពីរថយន្តដើរទៅសុីបសួររកផ្ទះហ្លួងរតនសម្បត្តិ។ មានកូមាម្នាក់នៅទីផ្សារនោះចង្អុលប្រាប់ថាផ្ទះហ្លួងរតនសម្បត្តិ នៅឯណោះ ចម្ងាយពីទីផ្សារនេះទៅប្រហែល ៥០០ម៉ែត្រ ក្បែរមាត់ផ្លូវសងខាងជើងនៅក្លោងទ្វារផ្ទះនោះមានសរសេរឃើហោ "គ្រឹះស្ថានរតនសម្បត្តិ" អញ្ជើញទៅចុះគង់នឹងឃើញមិនខាន។ ចៅចិត្រក៏ចេញដើរទៅតាមពាក្យកូមានោះ ហើយទៅឈររេរា

នៅមុខផ្ទះ ដូចមានឃីហោខាងលើនេះមួយស្របក់ ក៏មានកម្មករម្នាក់ចេញពីក្នុងភូមិនោះមកសួរថា "អញ្ជើញមករកអ្នកណា?"

ចៅចិត្រភ្ញាក់ព្រើត ព្រោះពេលនោះកំពុងឈរមើលភូមិប្រទេសយ៉ាងភ្លើតភ្លើនស្រាប់តែក្រឡេកឃើញបុរសខ្មៅម្នាក់ឈរស្ទួរក្បែរខ្លួន ទើបប្រាប់ទៅថា "ខ្ញុំមករកហ្លួងរតនសម្បត្តិ វេលានេះលោកនៅឬទេ?"

បុរសនោះឆ្លើយតប "លោកនៅខាងលើផ្ទះ បើចង់ជួបនឹងលោក អញ្ជើញមកតាមខ្ញុំ" ហើយបុរសនោះក៏ដើរនាំមុខចៅចិត្រឡើងទៅលើផ្ទះ។

គេប្រាប់ឲ្យចៅចិត្រអង្គុយលើកៅអីមួយនៅក្នុងបន្ទប់ទទួលភ្ញៀវ ហើយដើរចូលទៅក្នុងបាត់មួយស្របក់ ក៏លេចមនុស្សចាស់សក់ស្កូវម្នាក់ដើរចេញមកដោយឫកពាអង់អាច ស្លៀកសារុងសូត្រពាក់អាវទ្រនាប់តាមទំនៀមអ្នកនៅផ្ទះ ពាក្យដំបូងដែលនិយាយនឹងចៅចិត្រនោះគឺដូច្នេះថា "ក្មួយមកពីណា? ត្រូវការជួបនឹងខ្ញុំមានការអ្វី?"

ចៅចិត្រសង្កេតដឹងច្បាស់ថា លោកនេះហើយដែលហៅថា ហ្លួងរតនសម្បត្តិ ដែលខ្លួនត្រូវការជួប ទើបរំកិលខ្លួនចុះពីកៅអី បន្ទន់ខ្លួនសំពះដោយសេចក្ដីគោរពគួរសម។

ឯហ្លួងរតនសម្បត្តិ ជាអ្នកជំនួញលក់ត្បូងដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងស្រុកបប៉ៃលិនក៏អង្គុយលើកៅអីមួយ ចៅចិត្រសង្កេតតាមឫកពារបស់លោកនេះ យល់ថាជាអ្នកមានអធ្យាស្រ័យល្អ ចិត្តសប្បុរសគួរជាទីគោរពរាប់អានមែន។

"ទានប្រោស មាន!" ចៅចិត្រឆ្លើយដោយឱនលំទោនហើយថា "លោកគ្រូពេទ្យស្អាតបានផ្ញើសំបុត្រ១ច្បាប់មកជួបព្រះតេជព្រះគុណ"។

"អើ! ពេទ្យស្អាត ក្មួយខ្ញុំនោះឬ?" លោកនិយាយទាំងញញឹម តាមដោយលោកជាអ្នកមានអធ្យាស្រ័យរីករាយជានិច្ច ហើយសួរថា "សំបុត្រនោះ នៅឯណា?"

ចៅចិត្រលូកដៃទៅក្នុងហោប៉ៅយកសំបុត្រនោះជូនទៅលោកហ្លួង លោកហ្លួងទទួលយកទៅអានដោយសេចក្ដីត្រេកអរ លុះមើលចប់ហើយក៏បែរមកពិចារណាមើលលក្ខណៈចៅចិត្រម្ដងទៀត។

ហ្លួង៖ "ក្មួយឯងមែនទេ ឈ្មោះចៅចិត្រ ដែលពេទ្យស្អាតបានបញ្ជូនខ្លួនមកឲ្យខ្ញុំ?"

ចិត្រ៖ "ទានប្រោស ខ្ញុំបាទនេះហើយ"

ហ្លួង៖ "ចុះក្មួយធ្វើការយ៉ាងនេះបានដែរឬ? ការរបស់ខ្ញុំនេះវាធ្ងន់ណាស់ តោងទ្រាំជីកដីក្នុង១ថ្ងៃ ៥ ទៅ៦ម៉ោងទើបស្ទុះរួច រូបរាងស្អាតបាតដូចជាក្មួយនេះ ខ្ញុំយល់ថាទ្រាំទ្រការងារមិនបានយូរប៉ុន្មានទេ មុខជារត់ទៅផ្ទះវិញហើយ!"។

"មនុស្សដទៃទៀត គេទ្រាំធ្វើយ៉ាងណា ឯខ្ញុំបាទគង់តែធ្វើបានដូចជាគេដែរ សូមព្រះតេជព្រះគុណកុំព្រួយឲ្យសោះ!" ចៅចិត្តពោលរ៉ាប់រងយ៉ាងម៉ឺងម៉ាត់។ ពាក្យនេះហើយដែលធ្វើឲ្យហ្លួងរតនសម្បត្តិមានសេចក្ដីពេញចិត្តណាស់។ ហើយចៅចិត្រនិយាយតទៅទៀតថា "ទានប្រោស! មនុស្សដែលកើតមកក្នុងលោកសន្និវាសនេះ មិនប្រកាន់ការស្រោលៗ ស្រួលៗទេ ខ្ញុំបាទមិនដែលគិតដូច្នេះទេ

កាលបើខ្ញុំបាទមានកំលាំងពលំដរាបណា ខ្ញុំបាទនឹងខិតខំធ្វើការដរាបនោះ ទោះបីធូន់ក្តីស្រាលក្តី"។
"អ្នកឯងនិយាយនេះត្រូវណាស់" លោកហ្លួងនិយាយសរសើរ ហើយថា "ណ្ហើយចុះ! ឯខ្ញុំតែងមានការសម្រាប់មនុស្សដែលចង់ធ្វើជានិច្ច វេលានេះអណ្តូងត្បូងទិសខាងកើតខ្ញុំ កំពុងឲ្យចាប់ផ្តើមជីកត្បូងមានតំលៃមួយអន្លើ ព្រឹកស្អែកនេះខ្ញុំនឹងបញ្ជូនអ្នកឯងឲ្យទៅធ្វើការនៅទីនោះ ធ្វើការក្នុងគ្រាដំបូងនេះខ្ញុំនឹងតាំងប្រាក់ខែឲ្យអ្នកឯងត្រឹម៣០រៀលសិន ប៉ុន្តែអ្នកឯងអាចមានប្រាក់ខែច្រើនជាងនេះទៅទៀត បើខំយកចិត្តទុកដាក់ធ្វើការដោយម៉ឺងម៉ាត់ហើយម័ត់ចត់ផង"។
ចៅចិត្រឱនក្បាល ទទួលយល់ព្រមដោយសេចក្តីគោរពម្តងទៀត។

ក្នុងខណៈនោះមានសូរស្បែកជើង លាន់ឮពីខាងក្រោមឡើងមកលើផ្ទះ ព្រមទាំងមានសំលេងយ៉ាងផ្ទារតូចលាន់រំពងមកពីខាងក្រោយចៅចិត្រ។ ចៅចិត្រក៏ចោលភ្នែកក្រឡេកមើលទៅប្រទះនឹងភ្នែកទាំងគូកំពុងតែសំលឹងត្រង់ចំមកជាដួងភ្នែកប្រកបដោយទឹកដមគួរជាទីចាប់ចិត្តស្នេហា គេមានឫកពាឆ្មើងឆ្មៃបន្តិច មានកិរិយាក្និកក្នក់ ញ៉ែងញ៉ង ល្វាសល្វន់ល្អណាស់ សម្បុរស្បែកសស្អាត មុខមូលក្រឡង់ដូចវង់ព្រះចន្ទ្រា សូរសំឡេងស្រួយស្រស់ដូចសូររគាំងប្រាក់ ដំនើរល្វាសល្វន់ដូចផ្កាកុលាបដែលត្រូវខ្យល់បក់ល្វិចៗ នៅកណ្តាលសួនច្បារដូច្នោះ ឱ! ល្អអីល្អម្ល៉េះ! នេះប្រហែលជាអញយល់សប្តិឃើញទេដឹង?

ចៅចិត្រភ្ញាក់ស្មារតី លែងសំឡឹងស្រឡាំងកាំងក្នុងពេលដែលលោកហ្លួងស្រែកហៅកូនស្រីនោះឲ្យឡើងមកខាងលើផ្ទះ "មកឯណេះនារី! ថ្ងៃនេះ ប៉ាបានមនុស្សចូលមកធ្វើការថ្មីម្នាក់ទៀតហើយ"។
នាងក្រមុំនារីឈានជើងឡើងជណ្តើរមួយៗ ភ្នែកសំឡឹងមើលចៅចិត្រដោយកិរិយាឆ្មើងឆ្មៃបន្តិចដែលជាទំនៀមទំលាប់របស់ស្រីក្រមុំរូបស្រស់ ហើយសួរទៅឪពុកថា "ប៉ា! នេះជាអ្នកចូលមកធ្វើការថ្មីរបស់យើង?"
លោកហ្លួងញាក់មុខទទួលហើយងាកទៅនិយាយនឹងចៅចិត្រថា "ចៅចិត្រ នេះនារីកូនស្រីតែមួយរបស់ខ្ញុំ"។
ចៅចិត្រលើកដៃសំពះសួរនាងនារី នាងនារីងក់ក្បាលទទួលគំនាប់ដោយកិរិយាឆ្មើងៗតាមនិស្ស័យរបស់នាង។
នាងនារីសំលឹងមើលកម្មករថ្មីរបស់ឪពុកតាំងពីក្បាលរហូតដល់ចុងជើង មើលហើយមើលទៀត នៅទីបំផុតក៏លាន់មាត់ថា "កម្មករនេះស្គមដូចអ្នកញៀនអាភៀន នឹងមានកំលាំងជីកដីបានឬប៉ា?"
ចៅចិត្រកាលត្រូវស្រីក្រមុំស្តីដាក់មុខដូច្នេះក៏នឹកអៀនខ្មាស់ណាស់ ក្រឡេកចោលកន្ទុយភ្នែកទៅខាងមួយភ្លែត ហើយតបទៅថា "មនុស្សត្រង់ គេមិនដែលសំគាល់ថាជាមនុស្សល្ងង់ទេ ឯមនុស្សស្គមក៏គេមិនសំគាល់ថាជាមនុស្សខ្សោយដែរ ស្គមយ៉ាងខ្ញុំបាទនេះ មានកម្លាំងខ្លាំងដូចមនុស្សធាត់មាំដែរ គ្រាន់តែមិនសូវមានសាច់ឈាមធាត់បរិបូណ៌ប៉ុណ្ណោះទេតើ!"

នាងនារីធ្វើមុខក្រញូវទំនងខឹងបន្តិចៗផង ដោយនាងមិននឹកថាចៅចិត្រហ៊ានឆ្លើយដូច្នេះសោះ ព្រោះមិនធ្លាប់មានមនុស្សណាមួយក្នុងផ្ទះហ៊ាននិយាយលេងសំដីរោហារនឹងនាងឡើយ។

លោកហ្លួងឃើញកូនខឹងដូច្នេះ ក៏បញ្ឈប់ថា "ចៅចិត្រ! ឈ្លើយឈប់ស្លេះប៉ុណ្ណឹងសិនចុះ ឯងកំពុងនឿយហត់អស់កម្លាំង ទៅរកសំរាកខ្លួនអោយបាត់នឿយហត់សិនទៅ"។

# វគ្គទី ៣

## ចៅចិត្រកើតគំនិតថ្មី

តាំងពីថ្ងៃនោះមក ចៅចិត្រក៏បានធ្វើជាកម្មករជីកត្បូងនៅគេហដ្ឋានរបស់លោកហ្លួងរតនសម្បត្តិ ទោះបីការនោះជាការធ្ងន់ក៏ដោយ ចៅចិត្រក៏ឥតមានចិត្តធុញទ្រាន់ តែងតែខំធ្វើការនោះដោយខ្មីឃ្មាតអស់ពីចិត្តពីថ្លើម មិនមាននឹកនាដល់សេចក្ដីនឿយហត់ឡើយ ។ ភាសិត១បទថា "ខ្លួនទីពឹងរបស់ខ្លួន" ដែលជាពាក្យបណ្ដាំរបស់បិតាចុងក្រោយបង្អស់ នោះនៅឮសូរកងរំពងក្នុងត្រចៀករបស់ចៅចិត្រ ហាក់ដូចជាមានទេវតានៅចាំខ្សឹបប្រាប់នឹងត្រចៀកជានិច្ច។ ការខំប្រឹងប្រែងធ្វើការយ៉ាងម៉ឺងម៉ាត់ឥតមានទម្រន់និងអធ្យាស្រ័យល្អរបស់ចៅចិត្រនោះ ជាហេតុធ្វើឲ្យពួកកម្មករធ្វើការផងគ្នាស្រឡាញ់រាប់អានជាច្រើន រហូតដល់ហ្លួងរតនសម្បត្តិក៏មានចិត្តមេត្តាក្មេងកម្លោះនោះជាច្រើនដែរ។

ចៅចិត្រចូលមកធ្វើការនៅផ្ទះលោកហ្លួងអស់វេលា៦ខែកន្លះមកហើយនោះ តែងបានជួបប្រទះនឹងធម្មជាតិថ្មីៗ ដូចជាព្រៃភ្នំ ក្រំថ្ម ព្រឹក្សាលតាវល្លិ៍ និង អាកាសស្រស់បរិសុទ្ធដែលជារបស់ចំលែកក្នុងជីវិតចៅចិត្រ តែដែលចំលែកយ៉ាងពន្លឹកជាងនេះទៅទៀតនោះ គឺយុនទារី ចៅហ្វាយក្រមុំរបស់ចៅចិត្រ ដែលជាស្ត្រីប្រកាន់ខ្លួនមានឫកពាឆ្មើងឆ្មៃហើយជានារីមានរូបឆោមយ៉ាងល្អឯកក្នុងស្រុកបប៉ៃលិនហាក់ដូចផ្កាកុលាបកំពុងរីកផ្សាយក្លិន ក្រអូបឈ្ងុយឈ្ងប់ក្នុងវស្សានរដូវ។ វេលាដែលចៅចិត្រអង្គុយក្នុងផ្ទះស្ងាត់ៗតែម្នាក់ឯង ច្រើនប្រមូលយករឿងអស់នេះមកគិតនឹកជានិច្ច ហើយនឹកឆ្ងល់តែម្នាក់ឯងថា ចុះហេតុដូចម្ដេចបានជាអញចេះតែរំពឹងនឹកដល់នាងក្រមុំនេះអីម្ល៉េះ ចុះអញជាប់ចិត្តប្រតិព័ទ្ធនាងក្រមុំនេះឬអី? អ៊ំា មិនបានទេ នាងនេះរូបឆោមល្អមែនហើយ ប៉ុន្តែឫកពាឆ្មើងឆ្មៃ ប្រកាន់ខ្លួនហួសពេកថែមទាំងមានសម្បត្តិស្ដុកស្ដម្ភណាស់ ហួសវិស័យឈោងតោងបេះ ប្រលេះយកបាន ចុះអ្នកមានប្រយោជន៍អ្វី ដែលអ្នកនៅខំនឹកដល់គេ ទុកជាខំទប់ចិត្តមិនឲ្យគិតដូចម្ដេច ក៏នៅតែមានកូនចិត្តរិះរេទៅរករូបបារម្មណ៍នោះទាល់តែបាន! នៅទីបំផុត ចៅចិត្រភាវនាថា "ខ្លួនទាបកុំតោង ដៃខ្លីកុំឈោងស្រវាឱបភ្នំ!"។

ចំនែកនាងនារីក៏ធ្លាប់គិតថា កម្មករថ្មីរបស់នាងនេះជាមនុស្សចម្លែកជាងគេ មិនចេះប្រចុបប្រចែងចៅហ្វាយនាយ និយាយត្រង់ទៅត្រង់មក ឥតចេះក្រែងចិត្តគេសោះ ថែមទាំងចេះនិយាយសំដីទាន់សម័យទៀតផង បានជានាងនឹកជឿថា កម្មករកម្លោះនោះបានរៀនសូត្រចេះដឹងច្រើនគួរសមដែរ។ ជួនកាលនាងបានឮសូរបុរសកម្លោះនោះស្រែកច្រៀងរាយទំនុកតាមការកំសត់របស់ខ្លួនក៏មានច្រៀងទំនុកជាយុវាភិរម្យ ជាពាក្យរំលឹកយុវជនក៏មាន ទើបនាងយល់ថាកម្មករកម្លោះនេះច្បាស់ជាចេញមកពីសាលាមធ្យមសិក្សាណាមួយជាប្រាកដ។

នៅវេលាព្រលប់ថ្ងៃនោះ ជាខាងរនោច ព្រះចន្ទ្រក៏រះឡើងព្រាងៗ មើលឃើញផែបមួយចំហៀង ផ្លុះពន្លឺពណ៌ប្រផេះគងចុងព្រឹក្សាយ៉ាងត្រចះត្រចង់ នារីចុះមកដើរលេងកំសាន្តចិត្តជាមួយនឹងស្រីបំរើម្នាក់នៅទីធ្លាសួនច្បារមុខផ្ទះដែលមានស្មៅរាបស្អាតដូចកម្រាលព្រំ នាងតែងតែចោលភ្នែកក្រឡេកទៅកូនផ្ទះមួយដែលថៅចិត្រស្នាក់នៅនោះជារឿយៗ។

ពេលនោះនាងបានឃើញផ្ទះនោះងងឹតឥតពន្លឺភ្លើងទើបនាងនាំក្មេងស្រីបំរើ ហើយលបដើរឆៀងចូលទៅឈរនៅគុម្ពផ្កាដកខឺមខាងមុខបង្អួច ស្រាប់តែឮសូរសំលេងមនុស្សច្រៀងទំនុកយុវាភិរម្យយ៉ាងពិរោះចាប់ចិត្តថា:

*ពួកយើងជាគណៈយុវជន ស្រុះស្រួលលើសលន់ ទាំងប្រុសទាំងស្រីចូលយុវសាលា*
*ដែលទើបកើតថ្មី ប្រយោជន៍ដើម្បីជួយជ្រោមជ្រែងគ្នា។*

*ឲ្យបានចងបាច់ជាក្រុមមិត្តភក្តិ ស្រលាញ់រួមរ័ក្សជាសាមគ្គា សាមគ្គីទាំងជាតិយើងផងនានា*
*មេត្រីគ្រប់គ្នាជាសុខក្សេមក្សាន្ត។*

*គួរជួយអ្នកខ្សត់ឲ្យបានចេញទៅ ដើរមើលលំនៅសព្វទីភូមិឋាន មើលស្រែចំការនឹងច្បារឧទ្យាន*
*កិច្ចការប៉ុន្មានតោងចោងចាំទុក ... ។ល។*

វេលានោះ រស្មីចន្ទ្រកំពុងតែចូលមកតាមចន្លោះបង្អួចនិងចន្លោះទ្វារ ទើបនាងមើលទៅឃើញរាងកាយថៅចិត្រដេកលក់ស្ដូកស្ដឹងនៅទីនោះយ៉ាងច្បាស់លាស់ នាងក៏ស្រែកដាស់ថៅចិត្រពីរបីម៉ាត់ ថៅចិត្រក៏ប្រែខ្លួនស្ទុះក្រោកឡើងទាំងងងុយដេក កាលឃើញអ្នកដែលចូលមកដាស់ច្បាស់ ក៏ម្ទីម្នានិយាយអញ្ជើញឲ្យអង្គុយដោយកិរិយាឱនលំទោន។

"អញ្ជើញអង្គុយ យុននារី" ថៅចិត្រនិយាយព្រមទាំងលើកកៅអីមួយមកជូនអង្គុយហើយ និយាយថា "ការដែលយុនអញ្ជើញមកលេងផ្ទះខ្ញុំបាទ ខ្ញុំបាទមានសេចក្ដីត្រេកអរណាស់ ទុកដូចជាបានទទួលកិត្តិយសដ៏ខ្ពង់ខ្ពស់!"

នាងនារីធ្វើមុខក្រញូវបន្តិច ហើយស្ដីទៅថា "អ្នកណានិយាយថាខ្ញុំមកលេងនឹងអ្នកឯង?"

ថៅចិត្រសង្ស័យក៏សួរទៅវិញថា "ចុះយុនអញ្ជើញមកមានការអ្វី?"

នាងតបទៅវិញយ៉ាង កំបុតថា "ខ្ញុំមកស្ដាប់មនុស្សច្រៀងទេតើ ចុះអម្បាញមិញនេះអ្នកណាច្រៀងទំនុកយុវាភិរម្យក្ដែងៗក្នុងទីនេះ?"

ថៅចិត្រធ្វើឡឹងឡង់និយាយសួរនាងថា "ទានប្រោស យុវាភិរម្យជាអ្វី ជាសត្វឬជាមនុស្ស ខ្ញុំបាទមិនដែលឮឈ្មោះសោះឡើយ!"

នាងនារីខឹងឡើងមុខក្រហម ហើយប្រាប់ទៅថា "នែ! អ្នកភ្លើ យុវាភិរម្យជាទំនុកច្រៀង ខ្ញុំចង់ដឹងថាតើអម្បាញ់មិញនេះនរណាច្រៀង?"

ចិត្រ៖ "អេ! ទេ នរណាច្រៀងខ្ញុំបាទឥតដឹងសោះឡើយ តែខ្ញុំបាទមិនមែនច្រៀងទេ ឯខ្ញុំបាទនេះកុំថាដល់ទៅភ្លេងយុវាភិរម្យជាទំនុកទំនើបថ្មីអ្វីនោះឡើយ តែបទសករវាទីចុះផែអុំទូករាល់ឆ្នាំនោះ ខ្ញុំបាទក៏ឥតចេះនឹងគេសោះឡើយ"។

នារី៖ "កុំកុត! ខ្ញុំបានឮសូរសំលេងច្រៀងអំពីខាងលើផ្ទះនេះឯង ហើយនៅលើផ្ទះនោះក៏មានតែអ្នកឯងម្នាក់ឯងមែនទេ?"

ចិត្រ៖ "បាទ! មានតែខ្ញុំបាទម្នាក់ឯងមែន តែខ្ញុំបាទមិនមែនជាអ្នកច្រៀងទេ"។

"អ្នកឯងច្រៀងភ្លេងៗ នៅតែប្រកែកនឹងគេទៀត" នារីផ្ដួនពាក្យ។

ចៅចិត្រសើចហើយថា "ខ្ញុំបាទជំរាបហើយថាខ្ញុំបាទមិនចេះច្រៀងទេ ក៏នៅតែបង្ខំឲ្យច្រៀងទៀត។ យុននារី បើខ្ញុំបាទចេះច្រៀង ខ្ញុំបាទនឹងច្រៀងជូនយុនស្ដាប់ឥឡូវនេះឯង"។

នាងនារីនឹកខឹង ក្រោកឡើងឈរហើយថា "មនុស្សបែបនេះនិយាយខ្មែរមិនចេះស្ដាប់ទេ"។

ចិត្រ៖ "បើមិនចេះស្ដាប់ភាសាខ្មែរ ហេតុអ្វីក៏និយាយឆ្លើយឆ្លងគ្នាបាន?"

នារី "ឈប់ៗចិត្រ កុំនិយាយថ្លង់ណាស់" នាងលើកដៃហាម ហើយប្រុងនឹងចុះពីផ្ទះនោះទៅដោយរួសរាន់ តែចៅចិត្រអង្វរឃាត់ថា "ពុទ្ធោ! យុននារី យុនប្រញាប់ទៅណាភ្លាម?"

នាងឆ្លើយយ៉ាងសោះកក្រោះថា "ទៅគេង"។

ចិត្រ៖ "យុនកុំអាលអញ្ជើញទៅ យុនមិនគួរលះបង់ធម្មជាតិល្អៗដ៏ត្រកាល ដែលគួរពិតពិលរមិលមើលក្នុងវេលានេះទៅទេ!"

នារី៖ "ខ្ញុំក៏ចូលចិត្តធម្មជាតិល្អដូច្នេះដែរ តែស្អប់មនុស្សឆ្កួតព្រើលៗ"។

"នៅទីនេះឥតមានមនុស្សឆ្កួតទេ យុន" ចៅចិត្រខ្វិលនិយាយជជែកតទៅទៀត បែរជាបបួលដោយស្រួលថា "ណ្ហើយ យុន មិនបាច់និយាយជជែកគ្នាច្រើនទេ សូមអញ្ជើញទៅសន្ទនាលេងក្នុងសួនច្បារឯណោះ មើលធម្មជាតិល្អៗដ៏ត្រកាល កម្រមានណាស់!"

មិនដឹងជាអំណាចអ្វីមកគ្របសង្កត់ឲ្យនាងនារីធ្វើតាមពាក្យអញ្ជើញរបស់ចៅចិត្រ ស្រាប់តែចុះដើរនាំមុខទៅដោយស្រួល ទៅអង្គុយលើជើងម៉ាវែង ក្បែរដើមចំប៉ីមួយដើមជាមួយនឹងស្ត្រីបំរើរបស់នាង។ ឯចៅចិត្រក៏អង្គុយលើស្មៅក្បែរជើងម៉ាវែងនុះដែរ តែភ្នែករំពៃងើបមើលទៅព្រះចន្ទ្រាឆែបពាក់កណ្ដាលដួង ដ៏ដេរដាសទៅដោយពួកផ្កាយមានចំនួនច្រើនលើសលន់គណនា ហើយចៅចិត្រនិយាយឡើងថា "យុន គាប់ចិត្តពន្លឺស្មើដួងព្រះចន្ទ្រឬទេ?"

នារី៖ "ខ្ញុំចូលចិត្តដែរចិត្រ"។

ចៅចិត្រនិយាយដោយសំដីទន់ភ្លន់ថា "មែនហើយ! យុននារី ធម្មជាតិជារបស់ចំលែកនេះអាចប្រលោមលួងលោមអារម្មណ៍របស់មនុស្សយើងឲ្យបានសុខស្រួល ពន្លឺស្មើព្រះចន្ទ្រ ខ្យល់រំភើយផាត់និងក្លិន

ក្រអូបឈ្ងុយឈ្ងប់របស់ផ្កានានា អាចធ្វើចិត្តគំនិតរបស់យើងឲ្យមានអារម្មណ៍រីករាយទៅបានយ៉ាងចំលែក"។

នារីអង្គុយស្តាប់សំដីថៅចិត្រនិយាយដោយអារម្មណ៍អណ្តែតអណ្តូង នាងគិតថា "កម្មករកម្លោះនេះជាមនុស្សចម្លែកជាងកម្មករឯទៀតៗរបស់នាង សំដីគ្រប់ម៉ាត់របស់កម្មករនេះ ពេញទៅដោយសំនួនវោហារមុខគួរឲ្យចង់ស្តាប់ មិនសមជាមនុស្សខ្សោយចំណេះចេះដឹងទេ"។

នាងនារីស្ងាត់ទៅមួយស្របក់ ថៅចិត្តក៏ផ្តើមនិយាយឡើងមុនថា "បើយុននៅតែម្នាក់ឯង អង្គុយជាមួយនឹងធម្មជាតិបែបនេះ តើយុនធ្លាប់នឹកប្រវត្តិដល់ញាតិមិត្តសំលាញ់ដែលនៅឆ្ងាយៗខ្លះដែរឬ?"

នារី៖ "ខ្ញុំធ្លាប់នឹកដែរចិត្រ"។

ចិត្រ៖ "ខ្ញុំបាទក៏ធ្លាប់នឹកដែរ ហើយច្រើនតែជាប់នៅនឹងចិត្តជានិច្ចផង ឱ! យុននារី តាំងពីខ្ញុំបាទមកអាស្រ័យនឹងផ្ទះយុននេះ ខ្ញុំបាទមិនដែលឃើញអ្នកម្តាយរបស់យុនដល់ម្តងសោះ!"

នារី៖ "ខ្ញុំគ្មានម៉ែទេ ចិត្រ"។

ចិត្រ៖ "អេ! ចំឡែកដែរ បើយុនគ្មានម្តាយ ចុះយុនកើតមកដូចម្តេចបាន?"

នារី៖ "យីអើ! នែ គាត់ឯងកុំនាំអុចអាល បណ្តាលអោយកើតទោសាណ៎ា ពាក្យដែលថាគ្មានម្តាយនោះគឺថាម្តាយនោះគាត់អនិច្ចកម្មទៅហើយ យល់ទេ?"

ចិត្រ៖ "ឱ! ដូច្នេះទេឬ? យល់ហើយទានប្រោស តែយុនកាន់តែគ្រាន់បើជាងខ្ញុំបាទច្រើន!"

នារី៖ "អើ! ម្តាយគាត់ខូចទៅហើយដែរឬ?"

ថៅចិត្រធ្វើមុខស្រពោនហើយថា "យុន នៅគ្រាន់បើជាងខ្ញុំបាទច្រើន ព្រោះមានឪពុកបីបាច់រក្សា ចំណែកខាងខ្ញុំបាទគ្មានទាំងឪពុកទាំងម្តាយ"។

ត្រង់នេះ នាងនារីសង្កេតមើលទឹកមុខថៅចិត្រ ឃើញស្លុតស្រពោនទៅច្រើន ថៅចិត្រសន្សឹមៗងើបមុខមើលទៅមុខនាងហើយនិយាយថា "ប្រសិនបើធៀបខ្លួនយុនមកខ្ញុំបាទវិញ ហើយថែមទាំងជាស្ត្រីផង យុនតោងគិតថាការតស៊ូនឹងជីវិតដែលក្រីក្រលំបាកតោកយ៉ាកទៅតាមទំនើងតែម្នាក់ឯងនុះ តើវាមានរសជាតិដូចម្តេចខ្លះ? តែខ្ញុំបាទជាប្រុស ល្មមអត់ធ្មត់សេចក្តីលំបាកគ្រប់ៗយ៉ាង ហើយធ្លាប់តទល់នឹងសេចក្តីក្រីក្រតោកយ៉ាកមកច្រើនហើយ ជួនកាលខ្ញុំបាទអត់បាយពេញមួយថ្ងៃក៏មាន"។

នាងនារីអង្គុយសម្ងំស្ងៀមចាំស្តាប់ថៅចិត្រនិយាយ តែក្នុងចិត្តនឹកអាណិតអាសូរថៅចិត្រជាពន្លឹកហើយនឹកដល់ខ្លួនឯងថា បើអញត្រូវទទួលគ្រោះថ្នាក់យ៉ាងនេះឯង តើនឹងមានសេចក្តីលំបាកយ៉ាងណាទៅ?

នារី៖ "ចុះចិត្រមកនៅទីនេះ បានស្រួលខ្លះហើយឬនៅឡើយទេ?" នាងនិយាយតិចៗ ហើយមានសំលេងទន់ជាងមុនច្រើន។

ថៅចិត្រសំលឹងមើលភ្នែកនាងនារី ហើយញញឹមយ៉ាងពេះរាយឆ្លើយថា! "បាទ បានស្រួលច្រើន យុននារី តាំងអំពីខ្ញុំបានទទួលមកអាស្រ័យនៅក្នុងផ្ទះយុននេះ បានស្រួលឡើងច្រើន មិនបាច់នឹក

ព្រួយក្រែងអត់បាយស្លាប់ទេ បើបប៉ៃលិននៅតែមានមេត្តាខ្ញុំបាទយ៉ាងនេះជានិច្ចទៅ ខ្ញុំបាទមុខជាសូមធ្វើផ្ទឹងនៅតំបន់នេះជាប្រាកដ"។

អាកាសនៅបប៉ៃលិនតាមធម្មតាត្រជាក់ជាងស្រុកសង្កែបាត់ដំបងច្រើន បើជួនជាត្រូវរដូវរងាដូចក្នុងវេលានេះ ក៏កាន់តែត្រជាក់ខ្លាំងឡើងទៀតច្រើន លុះឮសូរទឹកសន្សើមធ្លាក់ចុះពីស្លឹកឈើមិនដាច់រយៈ ដួងចន្ទ្រមួយចំហៀងនោះក៏លិចបាត់បាំងដងភ្នំទៅ ខ្យល់ត្រជាក់កាន់តែបក់ផាត់ខ្លាំងឡើង ជាហេតុនាំអោយត្រជាក់ញាក់ដល់បេះដូងកម្លោះក្រមុំទាំងពីរនាក់ ទើបថៅចិត្រសន្សឹមក្រោកឡើងមើលទៅផ្ទៃមេឃដោយកិរិយាស្រពោនស្រពន់ ហើយនិយាយឡើងថា "យប់ជ្រៅហើយ យុននារី! អញ្ជើញឡើងទៅផ្ទះវិញចុះ អំណាចទឹកសន្សើមនិងខ្យល់រងាបែបនេះ អាចធ្វើឲ្យយុនផ្តាសាយ ឬទៅជាគ្រុនក៏សឹងបាន"។
នារីក្រោក ឡើងទៅលើផ្ទះដោយស្រួល ដូចកូនក្មេងដែលប្រដៅបានបែបបទល្អ តែនាងមកនឹកឆ្ងល់ក្នុងចិត្តថាកម្មករកម្លោះនេះមានអំណាចអ្វីហ្ន៎! អាចហ៊ានបង្គាប់អញ ឲ្យធ្វើតាមបង្គាប់ខ្លួនបានដោយងាយដូច្នេះ តែនាងក៏គិតយល់ថា "ប្រសិនបើអញនៅហាលសន្សើមយូរពេក អាចធ្វើឲ្យគ្រុនរងា ឬផ្តាសាយបានមែន"។

លុះដល់ព្រឹកឡើង ថៅចិត្រក៏លីចបដើរចេញទៅធ្វើការជីកត្បូងនាអណ្តូងត្បូងត្រង់ទិសខាងកើតដូចសព្វដងដែលធ្លាប់ធ្វើមករាល់ៗថ្ងៃ លុះបានដើរកាត់មុខផ្ទះធំនោះទៅ ស្រាប់តែឃើញនាងនារីនិងលោកហ្លួងរតនសម្បត្តិអង្គុយក្នុងរថយន្តយីហោរីណូត៍ ដែលជារថយន្តសម្រាប់ប្រើទៅទិញឥវ៉ាន់នៅផ្សារសង្កែ។ ឯតាសុនជាអ្នកបររថយន្តនោះ ខំប្រឹងវៃដៃទាល់តែបែកញើស ក៏នៅមិនឆេះសោះ ដល់យូរពេលណាស់ ទើបហ្លួងស្រែកសួរទៅថា "តាសុន រថយន្តមិនឆេះទេឬ?"។
តាសុនគ្រវីក្បាលយកកន្សែងជូតញើសមុខ ហើយជំរាបទៅលោកថា "មិនឆេះទេ ទានប្រោស! ខ្ញុំបាទបានដោះលាងសំអាតគ្រឿងអំពីយប់មិញនេះឯង ស្រាប់ តែព្រឹកឡើងវាគៀចដូច្នេះទៅ!"។
ថៅចិត្រដើរចូលមកជិតលើកដៃសំពះហ្លួងរតនសម្បត្តិ ហើយជំរាបសួរថា "ទានប្រោស ព្រះតេជព្រះគុណនឹងអញ្ជើញទៅឯណា?"
លោកតបទៅថា "ខ្ញុំទៅទទួលលោកបាឡាត់ស្រុកសង្កែបន្តិច តែរថវាមិនព្រមឲ្យទៅសោះ ថៅចិត្រ!"
នាងនារីសំលឹងមើលថៅចិត្រមួយភ្លែតឃើញទឹកមុខដូចជាស្រស់បស់ជាងសព្វថ្ងៃ មានកិរិយាអង់អាចខុសពីកម្មករឯទៀតៗ។
នារី៖ "ប៉ា យើងទៅមិនរួចទេឬអ្វី?" នាងសួរដោយសេចក្តីព្រួយ។

ចិត្រ "សុំឲ្យខ្ញុំបាទវៃមើលបន្តិច ក្រែងលោឆេះឡើងបាន" ហើយថៅចិត្របើកគ្របបាំងគ្រឿងយន្តពិនិត្យមើលមួយស្របក់ក៏ញញឹមហើយនិយាយថា "ទានប្រោស ទាស់ត្រង់ណោះ វៃម្តងទៀត ឆេះជា

ប្រាកដ" ហើយប្រាប់តាសុនឲ្យរវៃម្ដងទៀត។
តាសុនចាប់រវៃម្ដងទៀត គ្រឿងយន្តក៏គ្រហឹមគឹកកងមួយរំពេចឡើង អ្នកទាំងអស់គ្នាក៏ញញឹម តាសុនក៏ឡើងទៅទះស្មាថៅចិត្រ ហើយលាន់មាត់ថា "ពូកែគ្រាន់បើ អ្នកក្មួយអញ!"។

ហ្លួងរតនសម្បត្តិក៏លាន់មាត់ដោយសេចក្ដីត្រេកអរ ហើយសួរថៅចិត្រថា "ថៅចិត្រពូកែមែន រៀនចេះពីណា ប្រសប់លាក់ចំណេះណាស់?"
ថៅចិត្រនឹកត្រេកអរបង្អោនជំរាបទៅលោកថា "ទានប្រោស មិនបានរៀនឯណាទេ គ្រាន់តែធ្លាប់បររថយន្តមកដែរ ក៏ល្មមធ្វើកើតចំពោះតែគ្រឿងដែលខូចខាតតែបន្តិចបន្តួចប៉ុណ្ណោះ" ហើយចាប់ចបលើកលីលើស្មាប្រុងដើរចេញទៅ។
ឯតាសុនបានឮសំដីដែលថៅចិត្រថា "ធ្លាប់បររថយន្តមកដែរ" ក៏នឹកដល់ប្រពន្ធដែលទើបមកដល់ផ្ទះពីព្រឹកមិញនេះ គាត់មិនទាន់បានសាកសួរសុខទុក្ខសោះ ស្រាប់តែជាប់រវល់មកបររថយន្តជូនលោកហ្លួងទៅស្រុកសង្កែ ទើបគាត់ជំរាបសុំច្បាប់លោកថា "ទានប្រោស ថ្ងៃនេះខ្ញុំបាទមានធុរៈ ដ្បិតប្រពន្ធខ្ញុំបាទទើបមកដល់ផ្ទះព្រឹកមិញនេះ ខ្ញុំបាទមិនទាន់បានសាកសួរសុខទុក្ខ វាថាប្រញាប់វិលទៅស្រុកវិញក្នុងពេលវេលាថ្ងៃត្រង់នេះផង ដូច្នេះសូមព្រះតេជព្រះគុណាមេត្តាឲ្យថៅចិត្រ បររថយន្តជំនួសខ្ញុំបាទមួយពេលសិនចុះ"។
ហ្លួងរតនសម្បត្តិស្ងៀមមួយស្របក់ បែរទៅសួរថៅចិត្រថា "ចិត្រឯងបររថយន្តជំនួសតាសុន មួយថ្ងៃបានទេ?"
ថៅចិត្របែរទៅមើលមុខតាសុន ឃើញសំដែងអាការអង្វរ ទើបថៅចិត្រជំរាបទៅលោកថា "ខ្ញុំបាទបរជូនបាន ទានប្រោស!"។
តាសុនត្រេកអរណាស់ ស្ទុះទៅចាប់ដៃថៅចិត្រអង្រួនថា "អរគុណអ្នកក្មួយណាស់ សូមអ្នកក្មួយសំលាញ់ជួយយកតែបុណ្យទៅចុះ" ហើយគាត់ងាកមកលើកដៃសំពះលាហ្លួងរតនសម្បត្តិ ដើរចេញទៅ។

ថៅចិត្រយកគ្រឿងប្រដាប់ធ្វើការទៅទុកស្រេចហើយ ក៏ផ្លាស់សំពត់អាវកម្មករជាអ្នកបររថយន្ត ឡើងកាច់ចង្កូតបរចេញពីទីនោះទៅ ទំនងជាអ្នកឆ្លាតប៉ិនប្រសប់ដោយមិនមានឧបសគ្គរវាងពាក់កណ្ដាលផ្លូវ ដរាបមកដល់ស្រុកសង្កែ ដែលជាទីក្រុងបាត់ដំបង។
ឪពុកនិងកូនក៏ចុះពីរថយន្ត ដើរសំដៅទៅកាន់ផ្ទះមួយក្បែរសាលាស្រុក ប្រហែលកន្លះម៉ោងទើបឃើញនាងនារីចុះពីផ្ទះនោះមក។ ថៅចិត្រសួរដោយកិរិយាសុភាពថា "ត្រឡប់ទៅឥឡូវឬនៅទេ យុន?"
"នៅទេ" នាងតបកំបុតៗ ហើយថា "ចិត្រតោងទៅទិញអីវ៉ាន់ឯផ្សារជាមួយនឹងខ្ញុំឥឡូវ នុះកញ្ច្រែង! ចិត្រ កាន់យកទៅផងណ៎ា"។

ថៅចិត្រនឹកភាំងបន្តិច ដ្បិតតាំងអំពីកើតមក មិនដែលកាន់កញ្ច្រែងដើរតាមក្រោយស្រីណាម្តងសោះ តែគ្រានេះត្រូវតែធ្វើតាម ដ្បិតគេជាថៅហ្វាយខ្លួនឲ្យប្រាក់ខែខ្លួន គេឲ្យផ្ទះនៅ ទុកជាការធ្វើដូច្នេះនាំឲ្យអាម៉ាស់មុខយ៉ាងណា ក៏ត្រូវតែប្រតិបត្តិតាមបង្គាប់ទៅសិនចុះ ទើបនាយចិត្រតស៊ូកាត់កេរ្តិ៍ខ្មាស ចាប់កញ្ច្រែងត្រីដើរ៉ុយ តាមក្រោយថៅហ្វាយក្រមុំមានរូបឆោមស្រស់ប្រិមប្រិយនោះទៅ។

នារីបង្គាប់ "ចិត្រ ទៅសួរទិញត្រីរ៉ស់ធំៗពីរយកទៅស្ងោរជ្រក់ តើគេលក់មួយថ្លៃប៉ុន្មាន? រើសយកឲ្យជាត់ៗបន្តិច"។

ថៅចិត្រនិយាយសុំខ្លួនថា "សូមកុំប្រើឲ្យខ្ញុំបាទទិញឡើយ យុន!" ហើយនិយាយឆ្លើយតបទៅទៀតថា "តាំងពីកើតមក ខ្ញុំបាទមិនដែលទិញត្រីសាច់បន្លែបង្កាអ្វីទេ ក្រែងយុនបន្ទោសថាទិញថ្លៃពេក ដ្បិតខ្ញុំបាទមិនចេះតថ្លៃទិញត្រីទេ ទានប្រោស!"

នារីៈ "មិនអីទេ ទៅសួរទិញចុះ ចាំខ្ញុំតថ្លៃឲ្យ"។

ចិត្រៈ "សុំឲ្យយុនតថ្លៃទិញខ្លួនឯងចុះ"។

នាងនារីឡើងមុខក្រហមបន្តិច ក៏ដើរ៉ុយទៅទិញដោយខ្លួនឯង។ ឯថៅចិត្រក៏កាន់កញ្ច្រែងដើរតាមក្រោយ កាលទិញបានត្រីរ៉ស់ពីរដើរវិលទៅទិញរានឯទៀតៗ នាងនៅនឹកខ្នាញ់នឹងការចចេសរឹងរូសរបស់ថៅចិត្រណាស់ក៏ក្លែងដើរចេញពីរានមួយទៅរានមួយទៀត ដើររើរក់ចុះឡើងជាច្រើនបកច្រើនសាទិញអីវ៉ាន់ច្រើនស្ទេះស្ទះ ទាល់តែថៅចិត្រយកទៅស្ទើរតែមិនរួច នាងនឹកខ្នាញ់ក៏ខ្នាញ់ណាស់ តែនឹកចង់សើចក៏ចង់សើចណាស់ ដោយបានឃើញថៅចិត្រកាន់ពេញដៃទាំងពីរយួរផង ត្បៀតក្លៀកផងរណែងរណោង ហើយនាងធ្វើជាដើរវិលជាច្រើនបក ច្រើនត្រឡប់ទើបបត់ចូលទៅរថយន្ត។ ថៅចិត្រក៏ចេះតែដើរប្រកិតតាមក្រោយដរាបដល់រថយន្ត ហើយទំលាក់អីវ៉ាន់ទៅក្នុងរថយន្តនោះទៅ។ នាងនារីឃើញកិរិយាថៅចិត្រ ធ្វើដូច្នេះក៏ប្រឡេាតឡើងថា "យី! គាត់នេះ ក្លែងទំលាក់ឥវ៉ាន់លើក្បាលអញឬ?"

ថៅចិត្រឆ្លើយឡើងថា "សូមអត់ទោសទានប្រោស ធ្ងន់ពេក តែខ្ញុំបាទទំលាក់លើក្តាររថយន្តទេតើ"។

នារីៈ "ប្រយ័ត្ន គាត់ឯងកុំដើរកិរិយាថោកទាបពេក!"។

នាយចិត្រឮហើយគ្រាន់តែញញឹមហ៊ឹះៗ ហាក់ដូចជាមិនយកចិត្តទុកដាក់នឹងការខឹងសំបាររបស់ថៅហ្វាយក្រមុំនោះសោះ។

អ្នកទាំងពីរក៏អង្គុយនៅស្ងៀមទាំងអស់គ្នា ឥតនិយាយរកគ្នាមួយម៉ាត់សោះ មួយស្របក់ក្រោយមកទើបឃើញហ្លួងរតនសម្បត្តិមកដល់ទីចតរថយន្តជាមួយបុរសកម្លោះម្នាក់ មុខវែង ពាក់មួកស ពាក់អាវបើក-ក ចងក្រវ៉ាត់ ស្លៀកខោកាគីពាក់ស្បែកជើងពណ៌ក្រហម ស្រោមជើងស។ នាយចិត្រគ្រាន់តែក្រឡេកមើលទៅឃើញបុរសនោះ ក៏មានសេចក្តីទាស់ចិត្តឥតត្រេកអរបន្តិចបន្តួចឡើយ។

ហ្លួងរតនសម្បត្តិនិយាយថា "យើងតោងប្រញាប់ទៅឥឡូវទើបបាន បង្អង់យូរពេកមិនបានទេ ដ្បិត

យើងឥតដាក់កាំភ្លើងមកផងសោះ ក្រែងចោរប្លន់កណ្តាលផ្លូវ"។
នាងនារីបែរទៅញញឹមយ៉ាងផ្អែម ខណៈដែលបុរសកម្លោះនោះឡើងមកលើរថយន្ត ហើយសួរថា "លោកបាឡាត់ ដាក់កាំភ្លើងមកដែរឬ?"
ចៅចិត្រត្អូញរង៉ូវនៅតែក្នុងបំពង់ក "បុរសកំលោះនេះជាបាឡាត់ស្រុកសង្កែ រូបរាងបែបនេះមិនគួរសេពគប់សោះឡើយ កន្លែងអង្គុយវាលល្វឹងមិនអង្គុយ នៅតែទៅប្រជ្រៀតអង្គុយក្បែរឃុននារីក្រអើត!"
ចំណែកខាងលោកបាឡាត់ ទះគូថហើយប្រាប់ថា "ឃុននារី កុំព្រួយ មានកាំភ្លើងខ្លីជាប់មកជាមួយដែរ"។
ហ្លួងរតនសម្បត្តិក៏សើចថា "មានមួយប៉ុណ្ណឹងក៏ល្មមហើយ លោកបាឡាត់" ហើយងាកទៅប្រាប់ចៅចិត្រថា "ចេញទៅឥឡូវនេះចុះចៅចិត្រ បើចេញរថយន្តទៅវេលានេះ ប្រហែលជាម៉ោង៤រសៀលទើបដល់ផ្ទះយើង"។
ចៅចិត្រក៏ចុះទៅវៃតាមបង្គាប់ ហើយឡើងបររថយន្តចេញទៅសំដៅទៅតាមផ្លូវបប៉ៃលិន សឹងដេរដាសទៅដោយស្រែចំការច្បារដំណាំ លុះផុតពីភូមភ្នំសំពៅ ភូមិស្ទឹងកាលណា មានតែព្រៃព្រឹក្សាលតាវល្លិ៍ និងភ្នំក្រំថ្មដេរដាស ផ្លូវកាន់តែលំបាកឡើង ផ្ទៃផែនដីខ្ពស់ទាបៗ បត់បែនជាច្រើនជាន់ កាលចៅចិត្រក្រឡេកមើលមកក្រោយ ស្រាប់តែឃើញបាឡាត់ស្រុកនោះនិយាយក្អាកក្អាយសប្បាយចិត្តជាមួយនឹងនាងនារី ចៅចិត្រក៏កើតមោហាខ្លាំងឡើងថែមលើសសេចក្តីមួម៉ៅកាលដែលទៅផ្សារទិញត្រីនោះមួយជាន់ទៀត ក្លែងកាច់ចង្កូតអោយបត់ក្បាលធ្លាក់ទៅជង្ហុករាក់ៗមួយអន្លើនៅក្បែរផ្លូវ ម៉ាស៊ីនរោទិ៍រំពងព្រៃ ហើយទប់ង៉ក់ស្ងៀមនៅនឹងកន្លែងនោះឯង។

ចៅចិត្រក្រឡេកមើលក្រោយ ស្រាប់តែឃើញភ្នែកគ្រប់គូសំឡឹងមើលមកចំខ្លួន។ បាឡាត់ស្រុកភ្លាត់ធ្លាក់ពីទីអង្គុយ ហ្លួងរតនសម្បត្តិកំពុងយកដៃស្ទាបក្បាលដែលប៉ះទង្គិចនឹងដំបូលរថ នាងនារីផ្អៀងទ្រេតរិះតែធ្លាក់ តែជួនជាចាប់បង្អែកបាន។
លោកបាឡាត់បន្ទោស "សូហ្វ័រចង្រៃ បររថយន្តអីយ៉ាងអីចេះ"។
នាងនារីងាកដងខ្លួន ហើយបន្ទោសថា "ចិត្រ គាត់ឯងមិនចេះបរឡានទេឬអី?"
ចៅចិត្របែរទៅហ្លួងរតនសម្បត្តិ ហើយជំរាបថា "សូមអត់ទោស ទានប្រោស ប្រសិនបើខ្ញុំបាទមិនកាច់ចង្កូតឲ្យងាកទៅជង្ហុកទេ កង់មុខខាងស្តាំមុខជាប៉ះនឹងដង្គត់នោះជាប្រាកដ ហើយធ្វើឲ្យខូចពេលយូរជាងធ្លាក់ជង្ហុកនេះទៅទៀត"
លោកញាក់មុខទទួល ទំនងជាយល់ដូច្នោះដែរ ហើយចៅចិត្របែរមកមើលខាងក្រោយ ក៏ប្រទះនឹងភ្នែកដែលសំឡឹងសំឡក់ដាក់ជាច្រើនដង ច្រើនគ្រា ច្រើនត្រឡប់។

រថយន្តបរតទៅទៀតដូចធម្មតា តែនាងនារីសង្កេតយល់ដឹងដល់ជម្រៅចិត្តគំនិត្តរបស់ចៅចិត្រ តែកាលណានាងធ្វើជាស្និទ្ធស្នាលនឹងបាឡាត់ស្រុក នោះរថយន្តក៏ក្រលែងឃ្លេងឃ្លោងរកកល់ធ្លាក់ជង្ហុក ឬដើរខុសផ្លូវទៅ នាងស្ទើរតែមិនហ៊ាននិយាយអ្វីនឹងលោកបាឡាត់ទៀត។ តាំងពីនោះមក នាងក៏ដឹងខ្លួនថា ចៅចិត្រមានបំណងអ្វីក្នុងខ្លួននាង?

លុះរថបរផុតភូមិព្រៃផ្ដៅទៅឆ្ងាយបន្តិចក៏ទុកង៉ក់រលត់ម៉ាស៊ីន ទើបចៅចិត្រលោតចុះទៅ លើកគ្រឿងម៉ាស៊ីនមើល ស្រាប់តែធ្វើមាត់វៀចក្រវៃរ។ អ្នកជិះទាំងអស់គ្រប់ៗគ្នាមានសេចក្ដីព្រួយជាច្រើន ទើបហ្លួងរតនសម្បត្តិដែលមានសេចក្ដីព្រួយច្រើនជាងគេ ក៏ចុះពីរថយន្តទៅសួរចៅចិត្រថា "ម្ដេចទៅ ទៅទៀតបានឬទេ? ល្មមកែកុនបានឬទេ?"
ចៅចិត្រគ្រវីក្បាលដោយអស់សង្ឃឹម ហើយជំរាបទៅថា "ទានប្រោស បរទៅទៀតមិនបានទេ ខូចត្រង់កន្លែងសំខាន់ដែលខ្ញុំបាទធ្វើមិនកើត តោងទៅដួលចិនក្រឡឹងដាក់ជាថ្មីទើបបាន"។
នារីៈ "ម្ដងនេះស្រេច" ហើយនាងផ្ដេកខ្លួនលើពូករថយន្តដោយអាការអស់កម្លាំងជាច្រើន។
លោកបាឡាត់ចុះពីរថយន្ត ដើរមកឈរចំពីមុខចៅចិត្រហើយថា "គាត់ឯងបររថយ៉ាងម៉េចហ្នឹង ទាល់តែខូចរថអស់?"
ចៅចិត្រឆ្លើយខ្លីៗថា "ខ្ញុំបាទបរដូចយ៉ាងមនុស្សធម្មតា លោកក៏បានឃើញនឹងភ្នែកស្រាប់ហើយ"។
លោកបាឡាត់ខាំមាត់ហើយថា "បើគាត់ឯងមិនបរអោយធ្លាក់ជង្ហុកអម្បាញ់មិញនេះ ក៏គង់មិនខូចដល់ម្លឹងដែរ!"
ចិត្រៈ "លោកគិតថា ខ្ញុំបាទក្លែងបរឲ្យធ្លាក់ជង្ហុកឬអ្វី?"
បាឡាត់ៈ "ផ្លូវមានគរគោក ម៉េចក៏គាត់ឯងមិនបរឲ្យត្រង់ទៅតាមផ្លូវ មានតែគាត់ឯងក្លែងធ្វើឲ្យធ្លាក់ជង្ហុក?"
ចិត្រៈ "លោកថាដូចម្ដេចក៏បាន តែខ្ញុំបាទមិនបានក្លែងធ្វើឲ្យវាធ្លាក់ជង្ហុកទេ"
បាឡាត់ៈ "តោងប្រយ័ត្នសំដីបន្តិច គាត់ឯង"។
ចិត្រៈ "ខ្ញុំបាទបាននិយាយដោយសំដីគួរសមណាស់ហើយ ទានប្រោស"។
បាឡាត់ៈ "ម៉េចគាត់ឯងព្រហើនម្ល៉េះ ក្រែងគាត់ឯងគ្រាន់តែជាអ្នកស៊ីឈ្នួលគេទេ?"
ចៅចិត្រសើចចំអកបន្តិចហើយថា "ខ្ញុំបាទជាអ្នកស៊ីឈ្នួលគេមែន តែមិនមែនស៊ីឈ្នួលលោកបាឡាត់ទេ"។
ហ្លួងរតនសម្បត្តិនឹករំខាននឹងសំដីនិយាយជជែកគ្នានោះ ក៏ហាមប្រាមទៅថា "ឈប់និយាយប៉ុណ្ណឹងហើយ លោកបាឡាត់ ការនិយាយជជែកគ្នានៅគ្រានេះ វាមិនមានប្រយោជន៍អ្វីឡើយ បុរាណលោកថា សាបមួយដៃ ប្រៃមួយចិប មែនទេ?"
នារីៈ "ចុះយើងគិតធ្វើដូចម្ដេចទើបទៅដល់ផ្ទះ?" នាងសួរដោយសេចក្ដីព្រួយបារម្ភជាច្រើន ។
ហ្លួងៈ "ហ្នឹងហើយ ប៉ាក៏មិនដឹងគិតដូចម្ដេចដែរ"។

ថៅចិត្រដើរចូលទៅរកហ្លួងរតនសម្បត្តិ ហើយនិយាយជំរាបថា "យើងតោងរង់ចាំនៅទីនេះ ទំរាំមានរថយន្តណាមួយមកដល់ទីនេះ ប្រសិនបើគ្មានទេ ក៏តោងតែស្នាក់នៅទីនេះមួយយប់ បើនឹងដើរជើងទៅ ក្រែងតែពាក់កណ្ដាលអធ្រាតទើបដល់ផ្ទះ"។

លោកហ្លួងដកដង្ហើមធំ នាងនារីសួរលោកឪពុកដោយសេចក្ដីវិតក្កថា "យើងតោងតែដេកស្នាក់ក្នុងព្រៃនេះមួយយប់ទៅឬប៉ា ?"

ហ្លួងរតនសម្បត្តិញាក់មុខហើយថា "កូនឃើញទេ វេលានេះម៉ោង៤រសៀលហើយ ឬមួយកូនចង់ដើរលមើលក៏តាមចិត្ត"។

នាងនារីគ្រវីក្បាល ហើយថា "ទេប៉ា ទម្រាំដើរដល់កូនមុខជាស្លាប់ពាក់កណ្ដាលផ្លូវមិនខានឡើយ"។

ថៅចិត្រសើចឡើង នាងនារីបែរទៅសំឡឹងចំមុខ ហើយសួរថា "គាត់ឯង សើចអី!"

ថៅចិត្រញញឹមញញែមតាមធម្មតា ហើយថា "ខ្ញុំបាទសើចនឹងកំប្រុកមួយនោះទេតើ វាហាក់លោតពីដើមស្រម៉ទៅដើមកន្ទួតព្រៃ វាភ្លាត់ចំណាប់ធ្លាក់មកដល់ដីជិតប្រកាច់ បានខ្ញុំបាទសើចនឹងវា!"

នាងនារី ៖ "គេភ័យគេព្រួយរាល់គ្នា ឯងគិតតែពីសើចសប្បាយ"។

ចិត្រ៖ "បានជាខ្ញុំសើច ពីព្រោះសត្វនោះមានជើងដល់ទៅ៤ នៅតែភ្លាត់ចំណាប់ធ្លាក់ដល់ដីទាល់តែបានដូច្នេះទេតើ!"

នាងមិនឆ្លើយតបទៅវិញទេ គ្រាន់តែសំដែងអាការមិនគាប់ចិត្ត ប៉ុន្តែនាងធ្លាប់សំដែងកិរិយាដូច្នេះជានិច្ច។ ថៅចិត្រថ្មីកនឹងនិស្ស័យបែបនេះមកច្រើនគ្រាហើយ ទើបមិនមានចិត្តព្រួយបារម្ភអ្វី ថែមទាំងយល់ថាស្ត្រី កាលណាមិនសំដែងកិរិយាក្អិកក្អក់ខ្លះទេក៏មិនល្អមើលដែរ គ្រាន់តែកុំឲ្យជ្រុលហួសពេកប៉ុណ្ណោះ។

ឯនាងនារីនឹកប្រារព្ធនឹងខ្លួនឯងថា "កូនឈ្នួលកម្លោះនេះចំលែកជាងឈ្នួលដទៃទៀត ជាអ្នកមានអំនួតបន្តិច ថែមទាំងប្រើសំដីមិនចេះក្រែងចិត្តនរណាទេ តែវាចេះនិយាយសមហេតុសមផល ទើបនាងចូលចិត្តនិយាយឬដដែកពីរឿងអ្វីៗលេង"។

លោកបាឡាត់ដើរឆៀងមកក្បែរនាងនារី ហើយសួរថា "ចុះហេតុអីក៏យុននារីចូលចិត្តទៅនិយាយឆ្លើយឆ្លងនឹងអាក្មេងកម្លោះនោះម្ល៉េះ!"

នារី៖ "នរណាប្រាប់លោកថាខ្ញុំចូលចិត្តទៅនិយាយឆ្លើយឆ្លងនឹងវា!"

បាឡាត់៖ "ខ្ញុំបាទឃើញនឹងភ្នែក បានឃើញវានិយាយដដែកនឹងយុន ទាល់តែយុនទាល់ច្រកបស់វាម្លឹងៗហើយ នៅយុនទៅនិយាយដដែកនឹងវាទៀត វាក្មេងព្រហើនមិនចេះគួរសមទេ យុនពិនិត្យមើលវាឲ្យមែនទែនចុះ!"។

នាងនារីញាក់មុខទំនងយល់ដូច្នេះដែរហើយឆ្លើយថា "ចាំ កម្មករនេះព្រហើនបន្តិចមែន តែឧស្សាហ៍ធ្វើការណាស់"។

លោកបាឡាត់៖ "ប្រហែលជាវាទើបមកនៅទេ បានជាពីដើមមិនដែលឃើញសោះ"។

នារី៖ "ចាំ វាទើបនឹងមកនៅមែនប្រហែលជាង៦ខែប៉ុណ្ណឹង ឪពុកខ្ញុំគាត់មានចិត្តអាណិតមេត្តា ដោយ

ឃើញថាជាមនុស្សកំព្រាឪពុកម្ដាយ ហើយបានប្រគល់ឲ្យជីកអណ្ដូងត្បូងនៅទិសខាងកើតដែលទើបនឹងបើកថ្មី"។
និយាយគ្នាបានត្រឹមប៉ុណ្ណោះ ក៏ស្រាប់តែឮសំលេងហ្លួងរតនសម្បត្តិស្រែកហៅនាងនារី ហើយប្រាប់ថា "នារីកូន ចាត់ចែងដាំបាយទឹកទៅ ឪពុកនឹកឃ្លានបាយណាស់ ហើយឲ្យចៅចិត្ររកអុសភ្លើងផង"។
ចៅចិត្រចូលមកជិតហើយសួរថា "យុន នឹងឲ្យខ្ញុំបាទជួយធ្វើការអ្វីខ្លះ ចូរប្រាប់មកចុះ!"
នារី៖ "ទៅរកថ្មបីដុំមក ហើយរកអុសបង្កាត់ភ្លើងឡើងផង" នាងបង្គាប់ទៅលោកបាឡាត់ថា "លោកបាឡាត់អាណិតយកសាច់ដាក់កំប៉ុងមកឲ្យខ្ញុំពីរកំប៉ុង និងសណ្ដែកហូឡាន់តៅផង"។

កំឡោះទាំងពីរនាក់ក៏ធ្វើការផ្គាប់ផ្គននាងក្រមុំយ៉ាងម៉ឺងម៉ាត់ ឯចៅចិត្របានដុំថ្មតូចៗបីដុំ ហើយដាក់តំរៀបគ្នាជាមុំជើងក្រាន ហើយទៅរកកាច់អុសមកបង្កាត់ភ្លើងឆេះដង្គោលឡើង។
"យុន នឹងឲ្យខ្ញុំបាទធ្វើអ្វីទៀត" ចៅចិត្រសួរនាងខណៈដែលបង្កាត់ភ្លើងរួចហើយ។
នារី៖ "ចៀនត្រី ឆាសាច់គោនឹងសណ្ដែកទ្រើង អើ! យើងគ្មានខ្ទះទេ ចៅចិត្រតោងរកខ្ទះមក"។
ចិត្រ៖ "អេ ទានប្រោស ទីនេះមិនមែនផ្សារសង្កែទេ ចុះឲ្យខ្ញុំបាទទៅរកឯណាមកជូនយុនបាន?"
នាងដកដង្ហើមធំ ហើយប្រាប់ថា "អើ! នេះប្រុសត្រឡាំង ម្ដេចក៏មិនយល់ការអ្វីសោះ? ខ្ញុំគ្រាន់តែឲ្យទៅរកភាជន៍អ្វីមួយសំប៉ែតៗក៏បានហើយ សំរាប់យកមកចៀនឆាប៉ុណ្ណោះ"។
ចៅចិត្រញញឹមហើយថា "ប៉ុណ្ណឹងទេឬ!" ហើយស្ទុះក្រោកទៅឯរថយន្ត លើកពូកកម្រាលអង្គុយឡើងមើល ឃើញចានស្ពាន់សំប៉ែតៗ កាន់លើកបង្ហាញទៅនាងនារីថា "បែបនេះ បានឬទេ?"
តាំងអំពីចៅចិត្រចូលមកនៅជ្រកកោននឹងនារី នាងមិនដែលញញឹមម្ដងសោះ ទើបតែពេលនេះនាងក៏ញញឹមជំនួសពាក្យតបគ្រាដំបូង។
លុះលាងចានស្ពាន់រួចហើយ ចៅចិត្រក៏ដាក់លើជើងក្រានបណ្ដោះអាសន្ននោះឯង។
នារីក៏យកខ្លាញ់ជ្រូកដាក់ចៀនក្នុងចាននោះ ចៅចិត្រក៏យកស្លឹកត្នោតបក់ភ្លើងឲ្យឆេះឡើង ទាល់តែផេះហុយទ្រុបឡើង ទាល់តែនាងប្រាប់ឲ្យឈប់បក់។
ចិត្រ៖ "ហ្នឹងយុនគិតពិសាតែសាច់ទទេ មិនដាំបាយទេឬ?" ចៅចិត្រសួរនាងដោយហេតុ មិនឃើញនាងដាំបាយសោះ។
នារី "អើ មែនហើយ! ចិត្រ ខ្ញុំភ្លេចឈឹង ចុះយើងដាក់ឆ្នាំងឯណាដាំបាយហ្ន៎!" នាងនិយាយហើយសំឡឹងមុខចៅចិត្រ ទំនងសូមឲ្យជួយគិតគូរផង។
ចៅចិត្រដឹងទំនងក៏រត់ទៅឯរថយន្តម្ដងទៀត រកបានកំប៉ុងបៀរមួយធំ បើកជួសយកសាច់បៀរចេញខ្ចប់អស់ហើយ ក៏វិលមករកនារីសួរថា "បែបនេះប្រើបាន ទេយុន?"
នាងនារីញញឹមទទួលម្ដងទៀត ម្ដងនេះញញឹមចេញមកដោយសុទ្ធចិត្ត ឥតក្លែងបន្តិចឡើយ គ្រានេះហើយដែលចៅចិត្រឃើញថា យុននារីចៅហ្វាយក្រមុំរបស់គេនេះ មានកិរិយាទន់ភ្លន់ផ្អែមល្ហែមចំឡែក

ណាស់!

នារី៖ "ប្រហែលជាប្រើការបាន ចិត្រ" នាងតបទៅដោយសំដីធម្មតា "អើ! ចុះយើងបានទឹកមកពីណាដាំបាយហ់!"

ចិត្រ៖ "មិនអីទេ ទុកភ្នាក់ងារខ្ញុំបាទរកជូនឃុនទាល់តែបាន" ថាហើយក៏បើកបំពង់ទឹកក្នុងរថយន្ត ទឹកក៏ហូរចេញមកទាល់តែពេញកំប៉ុង ហើយយកមកឲ្យនាងនារី។ លោកហ្លួងលាន់សំដីពីក្នុងរថយន្តមកថា "ឆ្លាតគ្រាន់បើ បើមិនបានថៅចិត្រ ប្រហែលជាអត់បាយក្នុងពេលនេះទាំងអស់គ្នាមិនខាន"។

ឯលោកបាឡាត់ទទួលយកអាសាជាអ្នកដាំបាយ ដោយដឹងខ្លួនថាខ្លួនដូចជាចាញ់ប្រៀបថៅចិត្រច្រើនណាស់ ការដែលនៅស្ងៀមមិនជួយខ្វល់ខ្វាយនឹងគេ ស្រាប់តែបាយឆ្អិនបរិភោគនោះ ដូចជាមិនសមសោះ។

ឯថៅចិត្រតអំពីនោះមិនបានជួយធ្វើអ្វីទៀតទេ ទាល់តែបាយឆ្អិនទើបដួសបាយដាក់ចានត្រីចៀននិងឆាសាច់គោ យកទៅជូនហ្លួងរតនសម្បត្តិខ្លួនឯង នាងនារីបរិភោគនឹងស្លឹកឈើ ឯលោកបាឡាត់ស្រុកបរិភោគនឹងក្រដាសកាសែតដែលខ្ចប់ឥវ៉ាន់មកពីផ្សារសង្កែ។